# សង្គហធម៌ព្រះពុទ្ធសាសនា




**រៀបរៀងដោយ**

**ព្រះមហាមង្គលធម្មោ  មត~សុមឿន**

( សមណនិស្សិតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ, ភ្នំពេញ)

បោះពុម្ពលើកទី១ ចំនួន ៥០០ ក្បាល

**សម្រាប់ជាធម្មទាន**

**ព.ស.២៥៥២  គ.ស.២០០៨**

## មាតិកា

**ចំណងជើង** **ទំព័រ**

I-**អារម្ភកថា**.......................................**១**

II-**សេចក្តីផ្តើម**.................................. **៤**

III-**គួរចាប់ផ្តើមការរស់នៅដោយធម៌**............ **៩**

IV-**សង្គហធម៌៤យ៉ាង**.......................... **១២**

V-**សេចក្តីអធិប្បាយធម៌ទាំង៤យ៉ាង**............. **១៤**

**១~ទានៈ**.................................. **១៤**

**២~បិយវាចា**..............................**២៤**

**៣~លោកត្ថចរិយា**........................ **៤៤**

**៤~សមានត្តតា**............................**៦៥**

VI~**សេចក្តីសន្និដ្ឋាន**.............................**៨៧**

VII~**នាមសប្បុរសជនចូលបច្ច័យបោះពុម្ព**....... **៩៣**

# I-អារម្ភកថា

សៀវភៅដ៏តូចនេះ គឺជាស្នាដៃដំបូងរបស់ខ្ញុំដែលសរសេរឡើង ដើម្បីចូលរួមចំណែកក្នុងការបង្កើនបណ្តុះសតិបញ្ញាស្មារតី, អប់រំសីលធម៌, គុណធម៌ដល់មិត្តអ្នកអានដែលនិយមចូលចិត្តអានសៀវភៅ ក៏ដូចជាការចូលរួមក្នុងសង្គមមនុស្សជាតិផងដែរ។ សមិទ្ធផលដ៏តូចមួយនេះ ត្រូវបានកើតចេញពីសេចក្តីព្យាយាមរួមជាមួយនឹងបញ្ញាដ៏ទន់ខ្សោយរបស់ខ្ញុំ និងឆន្ទៈដ៏មុតមាំក្នុងការស្តារស្មារតីសីលធម៌, គុណធម៌សម្បទាដល់មនុស្សជាតិ។ ដូច្នេះហើយខ្ញុំសូមអភ័យទោសអំពីសំណាក់មិត្តអ្នកអានទាំងឡាយ ចំពោះកំហុសឆ្គងរបស់ខ្ញុំ ដែលកើតឡើងដោយអចេតនា ទោះតាមរយៈពាក្យពេចន៍ក្តី សំនួនវោហារល្បះប្រយោគ ឬ អក្ខរាវិរុទ្ធក្តី ព្រោះយ៉ាងណាក៏ដោយ សូមគិតថានេះជាឧបករណ៍សំរាប់បង្កើនបញ្ញា ឬ សំរាប់អានកំសាន្តបំបាត់ការអផ្សុកទៅចុះ។ ក្នុងនាមខ្ញុំអ្នកសរសេរ ខ្ញុំសូមទទួលនូវការរិះគន់ក្នុងន័យស្ថាបនា ដោយទឹកចិត្តស្មោះស្ម័គ្រពីសំណាក់មិត្តអ្នកអានគ្រប់ពេលវេលា។

ម្យ៉ាងទៀត,ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ





អ្នកដែលមានឧបការៈក្នុងការបោះពុម្ពសៀវភៅនេះ ដែលក្នុងនោះអ្នកដែលបានជួយកែអក្ខរាវិរុទ្ធមានដូចជាៈ

១-ភិក្ខុ **ឈួន-ល័ក្ខ** សមណនិស្សិត ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជនិងពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា

២-ភិក្ខុ **ភង-ស៊ីនួន** សមណនិស្សិត ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

៣-ភិក្ខុ **ឃឹម-សានីរាន** សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត (លេខាធិការវត្តមង្គលវ៉ាន)

៤-ភិក្ខុ **ខន-សុគន្ធី** សមណសិស្ស ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

និងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅផងដែរ ចំពោះលោកអ្នកសប្បុរសជន-ពុទ្ធបរិស័ទគ្រប់រូបទាំងអស់ ដែលបានចូលរួមវិភាគទានជាបច្ច័យដ៏ថ្លៃថ្លា ក្នុងការបោះពុម្ពសៀវភៅនេះឱ្យមានដំណើរការទៅបាន ជាពិសេសគឺព្រះតេជគុណ **ព្រះទេពសត្ថាឃើ-សុវណ្ណរតនា** សាកលវិទ្យាធិការរងនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ,ភ្នំពេញ និងជាព្រះចៅអធិការវត្តមង្គលវ៉ាន សង្កាត់

មនោរម្យ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ដែលបានអនុញ្ញាតឱ្យខ្ញុំព្រះករុណាបោះពុម្ព និងថែមទាំងបានជួយទំនុកបម្រុងយ៉ាងខ្លាំងទៀតផង។ ទាំងនេះសបញ្ជាក់ឱ្យឃើញថា ជាការរួមចំណែកដ៏ប្រពៃក្នុងវិស័យអភិវឌ្ឍន៏សង្គម ក៏ដូចជាវិស័យអភិវឌ្ឍន៏ធនធានមនុស្ស។ សូមប្រគេនពរ និងជូនពរអ្នកមានឧបការគុណទាំងអស់នេះ ឱ្យជួបប្រទះតែនឹងសេចក្តីសុខចំរើនកុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យព្រះពុទ្ធសាសនាបានរុងរឿងចំរើនតរៀងទៅ។

វត្តមង្គលវ៉ាន, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៨

អ្នករៀបរៀង

**ភិក្ខុមង្គលធម្មោ មត-សុមឿន**

"ការមានមិត្តគឺពិតជាសំខាន់ណាស់ តែបើមានតែមិត្តអាក្រក់ សុខចិត្តគ្មានទើបល្អជាង"





## II-សេចក្តីផ្តើម

ការរស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់គ្នាគឺតែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមកជានិច្ចទោះបីស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ។

ដោយសារតែភាពចាំបាច់ នៃទំនាក់ទំនងក្នុងការរស់នៅក្នុងសង្គមដែលត្រូវតែមាន ដូច្នេះហើយទើបយើងត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់នូវវិធីសាស្រ្តក៏ដូចជាមធ្យោបាយនៃទំនាក់ទំនងនេះ។ ជាទូទៅការរស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើងគ្រប់ៗគ្នាយើងក៏បានយល់ដឹងពិតប្រាកដមែនហើយ តែយើងនៅមិនទាន់បានកំណត់ ឬ ឱ្យតំលៃបានសមស្របទៅតាមអត្ថន័យពិតនៃពាក្យនេះនៅឡើយទេ។

ពាក្យថាទំនាក់ទំនងនៅក្នុងទីនេះ គឺសំដៅទៅលើទង្វើទាំងពាក្យសំដី កាយវិការ និងសកម្មភាពដែលត្រូវធ្វើចំពោះគ្នាទៅវិញទៅមក ជាពិសេសនោះគឺការចេះជួយយកអាសាគ្នា, ជួយធ្វើកិច្ចការគ្នា, ការផ្តល់កំលាំងចិត្តឱ្យគ្នា, ការផ្តល់យោបល់ឱ្យគ្នា, ការជួយណែនាំគ្នា,ការជួយជ្រោម

ជ្រែងឧបត្ថម្ភគ្នា និងការរាប់អានស្រឡាញ់ដល់គ្នានិងគ្នាជាដើម។

ជាការពិតណាស់,ការប្រើពាក្យថាទំនាក់ទំនងគ្នានេះក៏ត្រូវគ្នានឹងពាក្យបាលីផងដែរថា សង្គហធម៌ ដែលមានន័យមួយទៀតថា ធម៌សំរាប់សង្គ្រោះ ឬ ការជួយគ្នាទៅវិញទៅមកនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ផងដែរ។ នៅក្នុងព្រះពុទ្ធសាសនា ពាក្យនេះគឺជាពាក្យមួយដែលព្រះសម្មាសម្ពុទ្ធទ្រង់បានលើកយកមកសំដែងប្រកាសប្រាប់ដល់ពុទ្ធសាសនិកសាសនិការបស់ព្រះអង្គជារឿយៗ និងជាឧឡារិកហើយក៏ត្រូវបានអ្នកប្រាជ្ញទាំងឡាយ មានការជឿជាក់យ៉ាងមុតមាំហើយក៏បានទាំងប្រកាសផ្សព្វផ្សាយបន្ត ឱ្យមានបរិស័ទគោរពប្រតិបត្តិយ៉ាងច្រើនចាប់តាំងពី*សាសនានេះ*ត្រូវបានបដិសន្ធិឡើងនៅក្នុងលោក ដែលរហូតមកដល់ពេលនេះអស់រយៈកាលជាង២ពាន់ប្រាំរយឆ្នាំប្លាយមកហើយ។

យើងឃើញហើយថា,ការសំដែងនូវពាក្យនេះព្រះពុទ្ធអង្គក៏បានកំណត់បែងចែកទៅតាមប្រភេទមនុស្ស ឬ តាម





តួនាទីនៃមនុស្សដែរដូចជាសង្គហធម៌រវាងមាតាបិតាចំពោះបុត្រធីតា, បុត្រធីតាចំពោះមាតាបិតា, គ្រូចំពោះសិស្ស, សិស្សចំពោះគ្រូ, ចៅហ្វាយនាយ ឬ ចៅកែចំពោះអ្នកបំរើ, អ្នកបំរើចំពោះចៅហ្វាយនាយ, មនុស្សទូទៅចំពោះមនុស្សទូទៅជាដើម។

នៅទីនេះ, ខ្ញុំអ្នកសរសេរគ្រាន់តែសូមលើកយកចំនុចសង្គហធម៌របស់មនុស្សទូទៅចំពោះមនុស្សទូទៅ ត្រឹមតែមួយចំនុចប៉ុណ្ណោះមកនិយាយដើម្បីឱ្យសមស្របទៅនឹងទំហំសៀវភៅ។ ហើយម្យ៉ាងទៀតដោយយល់ឃើញថា ធម៌នេះមានសារសំខាន់ នៅក្នុងកិច្ចប្រតិបត្តិក្នុងជីវិតប្រចាំថ្ងៃរបស់យើងគ្រប់គ្នា ទើបខ្ញុំខំព្យាយាមស្រាវជ្រាវសរសេរទាំងមានពេលវេលាតិចតួច និងសេចក្ដីយល់ដឹងដ៏ស្តួចស្តើងរបស់ខ្ញុំផងដែរ។

ដោយយល់ឃើញថា ក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្សទូទៅមានលក្ខណៈចាំបាច់ ដែលត្រូវតែស្វែងយល់ពីមធ្យោបាយផ្សេងៗ នៃការទំនាក់ទំនងគ្នាទៅវិញទៅមក

**(Social Relations)** ដូច្នេះទើបខ្ញុំបានឆ្លៀតឱកាសពីការសិក្សាដ៏មមាញឹក សរសេរជាសៀវភៅដ៏តូចមួយនេះឡើងដើម្បីទុកជាជំនួយ និងជាប្រទីបបំភ្លឺបញ្ញាក្នុងការសិក្សាស្វែងយល់ដល់មិត្តអ្នកអាន។ ក្នុងនោះខ្ញុំបានជ្រើសរើសយកចំណុច **សង្គហធម៌ ៤ប្រការ** ដែលមានសំដែងនៅក្នុងព្រះពុទ្ធសាសនាមកសរសេរអធិប្បាយជាភាសាខ្មែរសាមញ្ញស្រួលស្តាប់ និងស្រួលអានដើម្បីសម្រួលដល់មិត្តអ្នកអាន គឺទាំងអ្នកធ្លាប់សិក្សាភាសាបាលីក៏អានបានអ្នកមិនធ្លាប់សិក្សាភាសាបាលីក៏អានបាន ហើយជាពិសេសគឺសៀវភៅខ្នាតតូចនេះ អាចតម្រូវដល់មិត្តអានបានទាំងចាស់ទាំងក្មេង ព្រោះថាខ្ញុំបានដកស្រង់នូវគំនិតរបស់អ្នកប្រាជ្ញល្បីៗនៅលើលោកមកបញ្ចូលនិងប្រវត្តិរបស់អ្នកតស៊ូខ្លះៗ និងពិសេសទៅទៀតនោះ គឺខ្ញុំបានលើកយកនូវតួយ៉ាងដ៏សំខាន់របស់ព្រះសម្មាសម្ពុទ្ធ រួមទាំងព្រះធម៌របស់ព្រះអង្គ មកបញ្ជាក់បន្ថែមទៀតផងដើម្បីឱ្យសមស្របនឹងចំណងជើងថា"សង្គមធម៌ព្រះពុទ្ធសាសនា"។ តើអត្ថន័យនៃពាក្យថា សង្គមធម៌ព្រះពុទ្ធសាសនាមានន័យសេចក្តីដូចម្តេច? ហើយតើអ្វីទៅដែលត្រូវបានគេហៅថា





សង្គហធម៌៤ប្រការ នោះ? តើមានអ្វីខ្លះ? ចុះវាមានប្រយោជន៍សំខាន់ប៉ុណ្ណាទៅ? ដូច្នេះដើម្បីបានយល់នូវរាល់បញ្ហាទាំងអស់នេះ សូមលោកអ្នកសាកល្បងអានសៀវភៅនេះ ដែលខ្ញុំនឹងធ្វើការអធិប្បាយរៀបរាប់ម្តងមួយៗតាមលទ្ធភាពចំណេះដឹងដែលខ្ញុំអាចធ្វើទៅបាន។

**"ការអានគឺជាចំណីនៃបញ្ញា ឯបញ្ញាគឺជាអាវុធសំរាប់ដោះស្រាយឧបសគ្គជីវិត"**



## III-គួរចាប់ផ្ដើមការរស់នៅដោយធម៌

កំណើតបានមកជាមនុស្សគឺជាកំណើតមួយដែលមានភ័ព្វសំណាងក្រាស់ក្រែលច្រើនពេកណាស់កន្លង។

ដូច្នេះហើយ យើងគ្រប់គ្នាគួរតែរក្សានូវតំលៃដែលមានដោយកម្រនេះឱ្យបានស្ថិតនៅគង់វង្ស និងកុំឱ្យធ្លាក់ទៅក្នុងសភាពដ៏ថោកទាបឱ្យសោះនោះគឺបានដល់ការចាប់ផ្ដើមជីវិតរស់នៅដោយការប្រតិបត្តិយកព្រះធម៌ធ្វើជាម្ហូប,ជាផ្ទះ, ជាស្បៀងអាហារ, ជាមិត្តសំឡាញ់, ជាទីពឹង និងជាគ្រឿងពិចារណាគ្រប់ពេលវេលាគ្រប់ដង្ហើមចេញចូលទាំអស់។

ពាក្យថា ព្រះធម៌នេះ បានន័យជាភាសាសាមញ្ញថាៈ សភាវៈទ្រទ្រង់សត្វលោកគឺបុណ្យ បាប, សុចរិត, ទុច្ចរិត, ហេតុ, សភាព, ធម្មតា, ប្រក្រតី, ប្រាជ្ញាញាណ, គុណ, សេចក្ដីចំរើន, អារម្មណ៍ខាងផ្លូវចិត្ត,ការរិះគិត,កិរិយាមារយាទ,ច្បាប់ជាដើម។ តាមសេចក្ដីដែលខ្ញុំបានដកស្រង់ចេញពីវចនានុក្រមរបស់ សម្ដេចព្រះសង្ឃរាជ ជួន ណាត មក ប៉ុណ្ណេះអាចបញ្ជាក់ឱ្យឃើញបានថា **ព្រះធម៌** គឺជាកិច្ចការ





សកម្មភាពទាំងឡាយ ដែលមនុស្សសត្វប្រព្រឹត្តធ្វើជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃរួមទាំងសភាពប្រក្រតីនៃចិត្តផងដែរ។

តែនៅក្នុងទីនេះ, ពាក្យថា **ព្រះធម៌** សំដៅយកតែសភាពដែលល្អ ដែលទ្រទ្រង់ឱ្យសត្វលោកប្រព្រឹត្តទៅបានសេចក្ដីសុខចំរើន ឬ គេអាចហៅម្យ៉ាងទៀតថា **គុណធម៌** នោះឯង។

ការរស់នៅប្រចាំថ្ងៃមនុស្សយើង គួរតែជាអ្នកធ្ងន់ក្នុងហេតុផល និងជាអ្នកស្រឡាញ់យុត្តិធម៌, ស្រឡាញ់សីលធម៌, ស្រឡាញ់សុចរិតភាព, ស្រឡាញ់រាប់អានគ្នា,ស្រឡាញ់សម្មាជីវៈ, ស្រឡាញ់ការឱ្យទាន, ស្រឡាញ់ការជួយយកអាសាអ្នកដទៃ, ស្រឡាញ់ប្រិយវាចា និងចេះបន្ទាបខ្លួនមិនប្រកាន់ឫកពាក្រអឺតក្រទមដាក់ញាតិមិត្ត ទាំងអស់នេះគឺជាអត្ថន័យពិតនៃពាក្យថា រស់នៅជាមួយព្រះធម៌ ឬ រស់នៅក្នុងម្ហូបនៃព្រះធម៌។

នៅក្នុងសៀវភៅនេះ ខ្ញុំសូមនាំអារម្មណ៍មិត្តអ្នកអានមកចាប់អារម្មណ៍ ក៏ដូចជាធ្វើការវិភាគទៅលើខ្លឹមសារធម៌៤

ចំណុច ដែលព្រះសម្ពុទ្ធទ្រង់បានសំដែងថា សង្គហធម៌ ឬ ធម៌ដើម្បីធ្វើការទាក់ទង ឬសង្គ្រោះគ្នាទៅវិញទៅមកនៅក្នុងសង្គម។ **ធម៌បួននោះគឺៈ ១-ទាន, ២-បិយវាចា, ៣-លោកត្ថចរិយា, ៤-សមានត្តតា** ដែលខ្ញុំនឹងលើកយកមកធ្វើអត្ថាធិប្បាយម្តងមួយៗដើម្បីបានជាប្រយោជន៍ ក្នុងការពិចារណាក្នុងជីវិត ក៏ដូចជាក្នុងការរស់នៅក្នុងសង្គមផងដែរ។

**"ស៊ូស្លាប់ខ្លួនកុំឱ្យស្លាប់ជាតិ ស្លាប់ខ្លួនកើតទៀត ស្លាប់ជាតិសោះសូន្យ"**





រៀបរៀងដោយ ព្រះមហាមង្គលធម្មោ មត-សុមឿន

## IV-**សង្គហធម៌៤យ៉ាង**

ជាធម្មតា,ការរស់នៅរបស់ជនគ្រប់ៗរូបតែងតែមានការពឹងពាក់ស្នាក់អាស្រ័យគ្នាទៅវិញទៅមក ទោះបីជាក្នុងសង្គមបែបណាក៏ដោយ។ ការដែលយើងត្រូវពឹងពាក់នេះមិនមែនមានន័យថាយើងមិនចេះធ្វើអ្វីសោះហើយដើរតែសុំអាស្រ័យនឹងគេនោះក៏ទេដែរ គឺយើងត្រូវតែស្រវាស្រទេញឱហាតឧស្សាហ៍ព្យាយាមធ្វើសព្វកិច្ចការសំរាប់ជីវិតខ្លួនយើងផ្ទាល់ និងមនុស្សដែលយើងត្រូវមើលថែទាំផង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ រឿងជីវិតមួយនេះពុំមាននរណាម្នាក់ដែលអាចកាត់ផ្តាច់ពីការពឹងពាក់នឹងអ្នកដទៃឡើយ គឺដាច់ខាតត្រូវតែមានក្នុងបញ្ហានេះសូម្បីតិច ឬ ច្រើនហើយទាំងដែលការពឹងពាក់នេះទៀតសោត ក៏ត្រូវតែមានភាពស្មោះត្រង់នឹងគ្នាជានិច្ច។

ហេតុដូច្នោះឯង, ទើបព្រះពុទ្ធជាម្ចាស់ដែលជាបុគ្គលប្រកបព្រមដោយគុណដ៏ច្រើនមាន ករុណាគុណ,វិសុទ្ធិគុណ និងបញ្ញាគុណជាដើម បើទោះបីស្ថិតក្នុងកាលៈទេសៈណា

ឬ មនុស្សប្រភេទណាក៏ដោយ ឱ្យតែព្រះអង្គបានជួបហើយ សំដែងធម៌ប្រោស ព្រះអង្គតែងតែលើកយកធម៌សំរាប់ទាក់ទងគ្នាក្នុងសង្គមពោលគឺ សង្គហធម៌នេះមកសំដែងដើម្បីឱ្យការប្រតិបត្តិមានការស្រឡាញ់រាប់អានគ្នា និងភាពរីកចំរើនរុងរឿងក្នុងសង្គម។ សូមមិត្តអ្នកអានសាកល្បងធ្វើការត្រិះរិះពិចារណាមើលក្នុងប្រទេស,សហគមន៍, តំបន់, ឃុំ,ខ័ណ្ឌ, ខេត្ត, ក្រុង ឬ ក្នុងគ្រួសារមួយ ប្រសិនបើគ្មានសង្គហធម៌ទាំងបួនមាន **ទាន, បិយវាចា, លោកត្ថចរិយា និង សមានត្តតា** ដែលព្រះពុទ្ធទ្រង់បានសំដែងនេះទេ តើនឹងទៅជាយ៉ាងណា? ខ្ញុំអ្នកសរសេរមានការជឿជាក់ថាពិតជាពុំមាន **សេចក្តីសុខ សុភមង្គល និងភាពរីកចំរើន**ឡើយ គឺបានត្រឹមតែជួបប្រទះនឹងសេចក្តីទុក្ខអន្តរាយ, វិនាសសាបសូន្យតែប៉ុណ្ណោះ និងជាសង្គមខ្វះតុល្យភាពសន្តិសុខ។



**"មានសាមគ្គីរស់ ខ្វះសាមគ្គីគឺច្បាស់ជាស្លាប់"**





## V-<u>សេចក្តីអធិប្បាយធម៌ទាំង៤យ៉ាង</u>

**១_<u>ទានៈ</u>** បានសេចក្តីថាការចែកឱ្យ,អំណោយ,ការប្រគេន,ការថ្វាយ,ការជូនជាដើម ដែលពាក្យនេះស្មើនឹងអង់គ្លេសថា Donation,gift, offer, distribution ដែលមានន័យប្រហាក់ប្រហែលទៅនឹងពាក្យថាជួយដែរ(Help)។

ជាការពិតណាស់ការឱ្យទានគឺជាមហាមន្តស្នេហ៍មួយដែលពូកែស័ក្តសិទ្ធិជាងមន្តស្នេហ៍សារិកាលិនថោងដូចដែលនេនទុំដាក់ចំពោះនាងទាវទៅទៀត ព្រោះថាវាអាចអន្ទងព្រលឹងដួងចិត្តរបស់មនុស្សដែលធ្លាប់តែកំណាញ់ស្វិត និងកំណាចឫស្យា,ដាច់ធម៌មេត្តា ឱ្យបែរជាមានចិត្តទោរទន់ស្លូបជ្រាយស្រឡាញ់ដូចក្រមួនត្រូវថ្ងៃបន្តិចម្តងៗ ដោយមិនដឹងខ្លួន។ ព្រះសម្មាសម្ពុទ្ធទ្រង់បានសំដែងថា "បើចង់យកឈ្នះមនុស្សកំណាញ់ស្វិត ត្រូវតែធ្វើទានជាមួយមនុស្សនោះឱ្យបានញឹកញយ"។ ខ្ញុំធ្លាប់បានឮពាក្យចាស់ប្រដៅកូនចៅថា "បើមិនស្រឡាញ់ ឬ មិនសេពគប់ជាមួយបុគ្គលណាម្នាក់ទេ គឺមិនត្រូវទទួលយកអំណោយ ឬ កាដូពីគេម្នាក់នោះឡើយ"

ព្រោះថាកាលបើយើងទទួលយកអំណោយពីគេញយៗយើងនឹងមានអារម្មណ៍ថាយើងជំពាក់គុណគេ ហើយយើងនឹងបាក់ចិត្តស្រឡាញ់គេដោយមិនដឹងខ្លួនជាក់ជាមិនខាន។

ធម្មតាទេ, និស្ស័យជាមនុស្សមានមន្ទិល និងមានការជាប់ជំពាក់ដោយការស្រឡាញ់ត្រេកអរ, ការខឹងសំបារ,នៅជាបុថុជ្ជនសាមញ្ញ រមែងពេញចិត្តទៅនឹងអ្វីដែលជាការបញ្ជោរសរសើរ និងការផ្គាប់ផ្គុនយកចិត្តពីអ្នកដទៃជានិច្ច គ្មាននរណាម្នាក់ដែលអាចគេចផុតពីសភាពបែបនេះឡើយ។ ប៉ុន្តែជានិច្ចកាលយើងតែងតែឮពាក្យគេនិយាយថាបុរសនេះចិត្តដែក **(metal-hearted)** នារីនោះចិត្តថ្ម **(rock-hearted)** តើនេះវាជារឿងពិតដែរឬទេ? ពិតតែមិនទាន់ត្រឹមត្រូវ១០០% នៅឡើយទេ។ ដោយហេតុថា,ដំបូងអាចធ្វើទៅបានដូច្នោះមែន តែមិនយូរប៉ុន្មានឡើយ បើគេនៅតែទទួលនូវការធ្វើល្អពីអ្នកដទៃ ដោយការពោលពាក្យសរសើរ, ពាក្យលួងលោម, ពាក្យផ្អែមល្ហែម, ពាក្យស្និទ្ធស្នាល និងការចែករំលែក,ហុចនេះហុចនោះ,ឱ្យនេះឱ្យនោះព្រឹកល្ងាចនោះ



រៀបរៀងដោយ ព្រះមហាមង្គលធម្មោ មត-សុមឿន

បេះដូងរបស់គេនឹងក្លាយជាទន់ជ្រាយស្អិតរមួតពេញដោយក្ដីស្រឡាញ់ក្តីអាណិតអាសូរក្ដីស្មោះស្ម័គ្រ និងការដឹងគុណយ៉ាងពិតប្រាកដ។

ក្នុងអត្តភាពជាមនុស្សសាមញ្ញដូចយើងគេរាល់គ្នានេះគ្មាននរណាម្នាក់ដែលថាមិនចេះកំណាញ់នោះទេ តែយើងត្រូវតែរៀនហាត់អប់រំចិត្តឱ្យចេះធ្វើទាន, ចេះជួយអ្នកដទៃ, ចេះធ្វើល្អដាក់គ្នាទៅវិញទៅមក ធ្វើយ៉ាងនេះឈ្មោះថាព្យាយាមកាត់បន្ថយសេចក្ដីអាក្រក់ក្នុងចិត្តផង ព្យាយាមកាត់បន្ថយសត្រូវនោះផង ហើយថែមទាំងបានឈ្មោះថាជាអ្នកសាងសន្ធំញាតិឱ្យបានច្រើនទៀត ព្រោះតាមរយៈការឱ្យទាននេះធ្វើឱ្យយើងសំបូរមនុស្សរាប់អានច្រើន មិនខ្វះគេគោរពកោតសរសើរ និងជាពិសេសគឺធ្វើឱ្យមានកំលាំងសាមគ្គីដ៏រឹងមាំមួយ ក្នុងទំនាក់ទំនងកិច្ចការសង្គមជាតិរវាងមនុស្ស និងមនុស្សក៏ដូចជាការសាងសន្តិភាពឱ្យពិភពលោកថែមទៀតផង។

យើងគ្រប់គ្នាបានឃើញស្រាប់ហើយ,នៅក្នុងជីវភាព

រស់នៅប្រចាំថ្ងៃ ដោយសារតែមនុស្សម្នាក់ៗឃើញតែពីចង់បាន និងលោភលន់មិនព្រមឆ្អែតស្កប់ស្កល់នឹងការមានបាន, ម្ល៉ោះហើយ គេមិនត្រឹមតែមិនព្រមចូលរួមធ្វើវិភាគទានឱ្យបានច្រើនក្នុងការអភិវឌ្ឍជាតិប៉ុណ្ណោះទេ តែគេថែមទាំងបានឆ្លៀតយកឱកាសល្អដើម្បីកេងយកចំណេញពីជាតិយ៉ាងសកម្មទៀតផងដូចជាហ៊ានលក់ជាតិ,ប្រព្រឹត្តអំពើពុករលួយ, កេងចំណេញពីប្រជាជនក្រីក្រ, ជួញដូរមនុស្ស, លក់គ្រឿងញៀន,គេចពន្ធដារជាដើម។ ទង្វើទាំងអស់នេះ គឺជារឿងដ៏អាក្រក់គួរឱ្យស្អប់ខ្ពើម និងគួរឱ្យអៀនខ្មាស់ណាស់ ប៉ុន្តែដោយសារការចង់បានបិទមុខទើបជំរុញឱ្យមនុស្សមួយចំនួនហ៊ានធ្វើ ព្រោះគេមិនមានចិត្តចែករំលែកនេះឯង។ *ទាន* គឺជាធម៌ផ្ទុយគ្នានឹង **លោភៈ** ឬ **មច្ឆរិយៈ** (សេចក្ដីចង់បាន និងការកំណាញ់)។ មិនបាច់ចាំនិយាយថ្វីដល់សង្គមជាតិ ឬពិភពលោកនោះទេ សូម្បីក្នុងសង្គមគ្រួសារមួយ ប្រសិនបើមានធម៌កំណាញ់ស្វិតនេះហើយ គ្រួសារនោះពិតជាមិនបានសុខឡើយ ព្រោះវាបានធ្វើឱ្យមានការតឹងតៀតជ្រុល,





មានការកិបកេងលួចលាក់, មានការមិនទុកចិត្តគ្នាទៅវិញទៅមក ម្ល៉ោះហើយសង្គ្រាមក្នុងគ្រួសារក៏ច្បាស់ជានឹងកើតឡើងជាក់ជាពុំខាន។ យើងពិតជាត្រូវការណាស់នូវសេចក្ដីសុខចំរើនទាំងសំរាប់ខ្លួនយើង, គ្រួសារយើង, ប្រទេសជាតិយើង និងពិភពលោកផងដែ។ ព្រោះតែហេតុដូច្នេះឯងទើបមានមនុស្សមិនតិចនាក់ទេបាននាំគ្នាទៅបន់ស្រន់បួងសួងសុំសេចក្ដីសុខចំរើន, សុំឱ្យមានទ្រព្យសម្បត្តិច្រើន និងប្រាសចាករោគា និងសុំឱ្យមានសន្តិភាពក្នុងពិភពលោកនេះពីព្រះសង្ឃដែលមានកិត្តិស័ព្ទល្បីល្បាញខាងមន្តអាគម ដោយការប្រទានទឹកមន្ត ឬក៏ចងខ្សែគាថា,ពីទេវតាឥន្ទព្រហ្ម និងជីដូនជីតាជាដើម។ តើបញ្ហាទាំងអស់នេះអាចនឹងកើតមានដែរឬទេ? ខ្ញុំអ្នកសរសេរយល់ថាពុំអាចទៅរួចទេ តែប្រសិនបើអាចទៅរួចនោះ ខ្ញុំក៏សូមជួយត្រេកអរដែរ ព្រោះខ្ញុំក៏ត្រូវការណាស់ដែរចំពោះចំនុចទាំងអស់នេះ។

នៅទីនេះ ស្មេរខ្ញុំគ្រាន់តែចង់ឱ្យអ្នកអានធ្វើការត្រិះរិះពិចារណាឱ្យបានហ្មត់ចត់ដើម្បីកុំឱ្យចាញ់បោកគេតែប៉ុណ្ណោះ

ព្រោះអីខ្ញុំធ្លាប់បានឃើញច្រើនណាស់ ចំពោះចំនុចទាំងអស់នេះ។ មានអ្នកខ្លះ ព្រោះតែចង់បានស្អាតឱ្យមនុស្សដែលខ្លួនស្រឡាញ់បាក់ចិត្តស្រឡាញ់ខ្លួនវិញ ម្ល៉ោះហើយខិតខំដើររកគ្រូល្បីៗធ្វើស្នេហ៍ចងខ្សែគាថាដាំសន្ទឹកមាសលើខ្លួនឱ្យដើម្បីចងចិត្តគេឱ្យជាប់ ហើយក៏មានអ្នកខ្លះទៀតខំបន់ស្រន់ដល់អស់ទេវតា, ឥន្ទព្រហ្ម, វត្ថុស័ក្តសិទ្ធិឱ្យជួយអន្ទងដួងចិត្តឱ្យគេអាណិតស្រឡាញ់ខ្លួនមិនតែប៉ុណ្ណោះទៀតសោត ក៏មានអ្នកខ្លះបានទាំងហ៊ានសំលាប់មនុស្ស(ស្ត្រីពេញក្រមុំព្រហ្មចារីយ៍) ដើម្បីបានធ្វើមន្តអាគមពូកែ ដាក់ឱ្យគេស្រឡាញ់ងប់លើខ្លួនតែផ្ទុយទៅវិញអ្វីគ្រប់យ៉ាងខាងលើនេះមិនដែលមានឃើញពិតប្រាកដក្នុងជីវិតរស់នៅឡើយ បានឃើញត្រឹមតែនៅលើកញ្ចក់ទូរទស្សន៍ ឬ នៅក្នុងសៀវភៅប្រលោមលោកតែប៉ុណ្ណោះឯង។

ហើយមួយវិញទៀត, អ្វីដែលជាការជឿងប់ងល់គ្មានបញ្ញានេះមិនត្រឹមតែមិនបានជាប្រយោជន៍ទេ តែថែមទាំងបានធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ខាតពេលវេលា និងធ្វើឱ្យ



រៀបរៀងដោយ ព្រះមហាមង្គលធម្មោ មត-សុមឿន

យើងខូះជំនឿដ៏ត្រឹមត្រូវ ពោលគឺរាងចាលលែងជឿនូវអ្វីដែលត្រូវ(ជឿខ្លាំង ឬស្រឡាញ់ខ្លាំងស្អប់ក៏ខ្លាំងណាស់ដែរ)។ ខ្ញុំសូមទោសដែលខ្ញុំនិយាយជ្រុលបន្តិចត្រង់ចំនុចនេះ ខ្ញុំពិតជាមិនមានចេតនាបង្ខូច ឬ បន្តុះបង្អាប់ដល់អ្នកដែលមានជំនឿងប់ងល់ក្នុងរឿងនេះទេ ព្រោះវាជារឿងដែលមានមកតាំងតែពីយូរយារណាស់មកហើយ ហើយថែមទាំងមានចំនែកល្អច្រើន ក្នុងការជំរុញឱ្យជីវិតមានភាពសុខសាន្តទៀតផង។ ប៉ុន្តែ អ្វីដែលខ្ញុំចង់និយាយឱ្យចំនៅពេលនេះ គឺថាមិនត្រូវអាងតែទៅលើចំនុចនេះទាំងស្រុង ឬ ច្រើនពេកនោះឡើយ ព្រោះវាធ្វើឱ្យយើងបាត់បង់នូវឱកាសក្នុងការបង្កើនគុណភាពជីវិតឱ្យរុងរឿងមានសុភមង្គល ហើយក៏កុំឱ្យយើងខ្ជិលច្រអូសដេកចាំព្រេងសំណាងតែម្យ៉ាងដែរ។ សូមចាំថា **មានតែយើងខ្លួនឯងទេ ដែលអាចសាងភាពរីកចំរើន និងសុភមង្គលឱ្យខ្លួនឯងបាន** អ្នកដទៃមិនអាចជួយយើងបានឡើយ បើទោះជាបានក៏តិចតួចណាស់ ហើយចាំបាច់ត្រូវមានសគុណទៀត ហើយបើយើងចង់ឱ្យគេស្រឡាញ់យើង

លុះត្រាតែយើងផ្តល់ឱ្យនូវសេចក្តីស្រឡាញ់របស់យើងទៅគេមុនដែរ នោះគឺត្រូវចេះធ្វើល្អដល់គេជាមុនសិន មានដូចជាផ្តល់ស្នាមញញឹមឱ្យគេសើចដាក់គេ, និយាយផ្អែមដាក់គេ, ស្មោះត្រង់នឹងគេជាពិសេសគឺត្រូវធ្វើទាននឹងគេឱ្យបានញឹកញយនេះជាព្រះពុទ្ធតម្រាស់។ អំពីបញ្ហាទាននេះ, ខ្ញុំក៏សូមបញ្ជាក់ផងដែរថា មិនមែនទាល់តែឱ្យរបស់របរអំណោយ, កាដូ, លុយកាក់, បាយទឹក, នំចំណីទើបឈ្មោះថាទាននោះទេ ព្រោះព្រះពុទ្ធបានសំដែងថា **ទាន** មានពីរគឺៈ **ធម្មទាន** ការឱ្យពាក្យប្រៀនដៅ ឬ ការសំដែងធម៌, បង្រៀនធម៌, ការអប់រំណែនាំ, ការផ្តល់យោបល់ជាដើម និង **អាមិសទាន** បានដល់ការឱ្យរបស់បរិភោគ, គ្រឿងស្លៀកពាក់, ទីកន្លែងស្នាក់នៅ, ថ្នាំព្យាបាលជម្ងឺ ឬក៏ វត្ថុផ្សេងៗ ដូចជាលុយកាក់ជាដើម។

ជាការពិតណាស់, ការឱ្យទានត្រូវតែធ្វើឡើងប្រកបដោយមេត្តាសុទ្ធចិត្ត, ករុណា, អាណិតអាសូរដោយស្មោះស្ម័គ្រ,ដោយក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ គឺថាមិនមែនឱ្យដោយ





ការបង្អួត ឬ ចង់បានការសរសើរពីអ្នកដទៃ ឬក៏ថា ដើម្បីបង្ហាញនូវភាពអស្ចារ្យរបស់ខ្លួននោះក៏ទេដែរ។

តាមធម្មតា,ការឱ្យទានទាំងឡាយណាដែលប្រកបទៅដោយភាពស្មោះស្ម័គ្រ, ភាពអាណិតស្រឡាញ់ ដែលបង្ហូរចេញពីក្នុងដួងចិត្តពិតៗនោះជាទានមានផលច្រើនទាំងនៅក្នុងបច្ចុប្បន្នភាព ក៏ដូចជាទៅអនាគតដែរ ព្រោះបើយើងនិយាយក្នុងបច្ចុប្បន្ននេះ អ្នកដែលត្រូវបានគេឱ្យទាន ឬ ធ្វើអំណោយចំពោះសូម្បីតិចតួចក៏ត្រេកអរដែរ ឱ្យតែអ្នកឱ្យនោះសំដែងនូវភាពស្មោះស្ម័គ្រ,ស្រឡាញ់,អាណិត, រួសរាយរាក់ទាក់ពិត ហើយគេក៏នឹងចងចាំជានិច្ចនូវគុណបំណាច់ដូចនេះហើយ គេនឹងផ្តល់នូវក្តីស្រឡាញ់ដឹងគុណចងចាំដោយស្មោះអស់ពីដួងចិត្ត ដល់ម្ចាស់អំណោយជានិច្ច។ តែគេនឹងមិនអាចចងចាំបានទេនូវគុណសូម្បីដ៏តិចតួច ឬ អាចនឹងធ្វើព្រងើយដើម្បីបំភ្លេចគុណឱ្យសូន្យតែម្តង ក៏អាចមានព្រោះតែគេមិនចង់ចងចាំនូវភាពល្ងីងល្ងូរចត់ ឬ ភាពសោះកក្រោះគំរោះគំរើយរបស់ម្ចាស់ទាននោះឡើយ ហើយជូន

កាលអាចបណ្ដាលឱ្យមានការចងគំនុំទៀតក៏សឹងមានដែរ។

បើដូច្នេះ,ការធ្វើទានយើងត្រូវតែតាំងចិត្តថាយើងធ្វើដើម្បីបានភាពសុខស្ងប់នៅក្នុងចិត្តរបស់យើងផង ដើម្បីចែករំលែកសេចក្ដីសុខឱ្យដល់អ្នកដទៃផង ដើម្បីរឹតចំណងសាមគ្គីក៏ដូចជាការផ្ដល់នូវក្ដីស្រឡាញ់ចំពោះអ្នកដទៃផង ហើយថែមទាំងចង់ឱ្យអ្នកដទៃឱ្យក្ដីសុខដល់ខ្លួនផង និងផ្ដល់នូវការស្រឡាញ់រាប់អានតបចំពោះខ្លួនវិញដែរ។ សូមមេត្តាចាំថា **យើងចង់បានសេចក្ដីសុខ, ការរាប់អាន, ការផ្ដល់កិត្តិយស, ការលើកទឹកចិត្ត និងការមិនរើសអើងពីអ្នកដទៃយ៉ាងណា ចំណែកឯអ្នកដទៃក៏ត្រូវការពីយើងវិញយ៉ាងនោះដែរ។**

ដូច្នេះហើយ,យើងក៏ត្រូវតែផ្ដល់ឱ្យគេនូវអ្វីដែលយើងចង់បានពីគេជានិច្ច។ **ការមិនរើសអើង និងការរួបរួមសាមគ្គីគ្នាជាហេតុនាំឱ្យមានសេចក្ដីសុខ ចំណែកការឱ្យទានគឺជាមហាមន្តស្នេហ៍ដ៏សក្ដិសិទ្ធជាទីបំផុត។ការឱ្យទានជាកំលាំងដ៏រឹងមាំនៃទំនាក់ទំនង ឯការផ្ដល់នូវក្ដីស្រឡាញ់ពេញចិត្តក៏រឹតតែជាជីវជាតិមួយដ៏សំខាន់ សំរាប់ចិញ្ចឹមនូវទំនាក់ទំនង**





**ឱ្យកាន់តែមានភាពរស់រវើកជានិច្ចគ្រប់ពេលវេលា និងគ្រប់ទីកន្លែង(ជីវិតពុំមែនអំនួត តែភាពស្លូតបូតជារសជាតិពិត)។**

**(ជីវិតត្រូវតែធ្វើការ, រៀនសូត្រ និង រីករាយ)**



**២_បិយវាចា:** បានដល់សំដីពីរោះ, សំដីមានខ្លឹមសារ, សំដីទន់ភ្លន់, សំដីមិនញុះញង់ចាក់ដោត, សំដីរួសរាយសុភាពរាបសាគួរឱ្យចង់ស្ដាប់,សំដីពោលពាក្យពិតទៀងត្រង់មិនមានពីសពុលជាដើម។

តាមធម្មតា, ពាក្យសំដីគឺជាមធ្យោបាយមួយដ៏សំខាន់សំរាប់ធ្វើការទាក់ទងក្នុងកិច្ចការងារផ្សេងៗ នៅក្នុងជីវភាពប្រក្រតីប្រចាំថ្ងៃ។ ដូច្នេះហើយយើងមិនគួរអីនឹងកំណាញ់

ទាល់តែសោះ ចំពោះការប្រើប្រាស់ពាក្យសំដី បិយវាចា ឬ ប្រិយវាចា ដែលជាវាចាដ៏មានជីជាតិធ្វើឱ្យអ្នកស្ដាប់ពេញចិត្តស្រឡាញ់ស្ម័គ្រស្មោះមេត្រី ចង់ស្ដាប់ហើយស្ដាប់ទៀតមិនចេះជិនណាយ ហើយថែមទាំងបានផលប្រយោជន៍ទៀតផង។ យើងឃើញថាមានមនុស្សមិនតិចនាក់ទេដែលប្រាថ្នាចង់ឱ្យគេគោរពស្រឡាញ់ រាប់អាន ចូលចិត្ត ផ្ដល់កិត្តិយសឱ្យជាពិសេសគឺចង់ឱ្យគេកោតសរសើរស្ញប់ស្ញែង, ម្ល៉ោះហើយគេបានខំប្រឹងប្រែងវាយឫកពាក្រអឺតក្រទម ឬ ខិតខំសំញែងសំលៀកបំពាក់, គ្រឿងប្រើប្រាស់ផ្សេងៗ ឬ ពុំនោះទេ គេខំរៀននិយាយឱ្យដូចអ្នកណាស់គ្មានអ្នកណាស្មើដើម្បីឱ្យគេមើលមកថាខ្លួនអស្ចារ្យ។ សូមមិត្តអ្នកអានមេត្តាគិតថាឥរិយាបថទាំងអស់នេះ គឺពិតជាគ្មានបានផលប្រយោជន៍អ្វីនោះឡើយ ហើយផ្ទុយទៅវិញរឹតតែធ្វើឱ្យគេកាន់តែស្អប់ទៅៗរកលេខដាក់គ្មាន ព្រោះតាមធម្មតាគ្មាននរណាម្នាក់ចូលចិត្តភាពព្រហើនកោងកាចឃោរឃៅក្រអឺតក្រទមសំដីគ្មានរសជាតិឡើយ។



រៀបរៀងដោយ ព្រះមហាមង្គលធម្មោ មគ-ស្មឿន

ក្នុងកិច្ចទំនាក់ទំនង,យើងទាមទារជាចាំបាច់នូវភាពឆ្លាតវៃប៉ិនប្រសប់ ប្រកបដោយទេពកោសល្យខ្ពស់ក្នុងការនិយាយស្ដី នោះគឺបានដល់វាចាដ៏ពីរោះទន់ភ្លន់ស្មោះត្រង់ប្រកបដោយភក្ដីភាពចេញពីក្នុងចិត្តពិតៗ និងការប្រើពាក្យសំដីត្រឹមត្រូវតាមកាលៈទេសៈ។ ចំណុចនេះ, ពុំមែនចង់និយាយថាទាល់តែមានសំឡេងពីរោះទើបអាចធ្វើឱ្យអ្នកដទៃចូលចិត្តស្ដាប់ហើយជឿជាក់តាមនោះទេ គឺចង់និយាយដល់ការបញ្ចេញវាចា ដែលប្រកបដោយភាពម៉ត់ចត់ម៉ឺងម៉ាត់មិននិយាយច្រើនឥតប្រយោជន៍ និយាយតែពាក្យណាដែលពិតហើយមានភាពរួសរាយស្រស់ស្រាយ, ទន់ភ្លន់ និងមិនចេះនិយាយបញ្ឆិតបញ្ឆៀង, ញុះញង់ចាក់ដោត ឬក៏ ពាក្យគំរោះគំរើយរម៉ោករម៉ាំងមិនដឹងខុសត្រូវឡើយ។

ជាការពិតមែនហើយ,ពាក្យសំដីជាប្រភពធ្វើឱ្យយើងដឹងពីមនុស្សម្នាក់បានថាគេជាមនុស្សប្រភេទណា ដូចពាក្យខ្មែរបុរាណពោលថា“សំដីសជាតិមារយាទសត្រកូល”ព្រោះសំដីដែលចេញពីមាត់មកនោះ គឺត្រូវបានឆ្លងកាត់ការត្រិះរិះ

ពិចារណារបស់អ្នកនិយាយ អីចឹងហើយបើអ្នកនិយាយគិតយ៉ាងណាសំដីក៏យ៉ាងនោះដែរ។

មួយវិញទៀត, យើងដែលជាអ្នកនិយាយត្រូវតែចងចាំថា"យើងពុំមែនពូកែតែនិយាយ តែមិនពូកែស្តាប់នោះទេ គឺត្រូវតែស្តាប់ពីគេឱ្យបានច្រើនជាងប្រការដែលយើងចេះតែនិយាយឱ្យគេស្តាប់នោះផង ព្រោះថាធម្មជាតិបានបង្កើតមនុស្សមកមានមាត់តែមួយ ឯត្រចៀកមានពីរ, ច្រមុះមានរន្ធពីរ,ភ្នែកមានពីរ ក៏ព្រោះតំរូវឱ្យស្តាប់, ហិតក្លិន និងមើលឱ្យបានច្រើនតែនិយាយឱ្យបានតិចនោះឯង"។

ក៏ដូចគ្នាដែរ, សំដីដែលនិយាយក៏មិនមែនដើម្បីឱ្យតែពីរោះស្តាប់តែមិនល្អគិតនោះក៏ទេដែរ គឺបានន័យថាសំដីដែលយើងនិយាយទាំងពីរោះស្តាប់ផង និងយកទៅគិតបានជាប្រយោជន៍ទៀតផង។ ពិតមែនហើយ, ជួនកាលយើងនិយាយដោយប្រើប្រាស់ពេលវេលាអស់យ៉ាងច្រើនតែយើងពុំទទួលបានផលប្រយោជន៍ដែលល្អ សូម្បីដ៏តិចតួចក៏ទេដែរ លើសពីនេះទៅទៀតធ្វើឱ្យយើងអស់កំលាំងហេវហត់ដោយ



រៀបរៀងដោយ ព្រះមហាមង្គលធម្មោ មត-សុមឿន

សារការនិយាយនេះ ហើយបែរជាមិនទទួលបានផ្លែផ្កាអ្វីថែមទាំងបានត្រឹមតែគេស្អប់ចងគំនុំ និងពេបជ្រាយថែមទៀតនេះក៏ព្រោះមកតែពីការនិយាយខុសកាលៈទេសៈ,ខុសបុគ្គល, ទាំងដែលការនិយាយនោះខុសទំនង មិនចំទិសដៅគំរោះគំរើយ,ឬប៉ប៉ាច់ប៉ប៉ោចគ្មានបានការ។ មាត់យើងមានតែមួយទេ ហើយក៏គ្មានពេលវេលា និង កំលាំងប៉ុន្មានឡើយ ដូច្នេះ យើងមិនគួរប្រើប្រាស់ពេលវេលាដ៏តិចតួចបែបនេះ និងកំលាំងរបស់យើងចោលទទេៗ ដោយការបង្ហូរចេញនូវអសារវាចាទាល់តែសោះគឺត្រូវតែប្រើប្រាស់នូវពេលវេលាឱ្យមានខ្លឹមសារដោយសំដីដែលពិតត្រឹមត្រូវ, មិនឡេះឡោះឥតការ,សុភាពទន់ភន់រួសរាយរាបសាជានិច្ច។ យើងមិនគួរអឺកំណាញ់នឹងពាក្យសំដីឡើយ តែយើងក៏មិនគួរយកពាក្យសំដីទៅចាក់ចោលដែរ យើងត្រូវតែគិតថាសំដីដែលចេញពីមាត់មកមួយម៉ាត់ៗគឺមានតំលៃប្រៀបដូចជាដុំពេជ្រដែលត្រូវបានគេឱ្យតំលៃ និងយកចិត្តទុកដាក់គិតគូរជាទីបំផុត។

ខ្ញុំអ្នកសរសេរមិនមែនចង់មានន័យថា,គ្រប់ពាក្យសំដី

ដែលនិយាយសុទ្ធតែឥតខ្វោះនោះទេ តែគឺខ្ញុំចង់ឱ្យអ្វីដែលសូម្បីរបូតចេញពីមាត់ដោយមិនដឹងខ្លួនក៏ត្រូវបានគេយកចិត្តទុកដាក់ស្តាប់ និងចង់ស្តាប់ ហើយយកទៅគិតបានផលល្អដែលប្រៀបបានទៅនឹងទឹកឃ្មុំ ដែលមិនត្រឹមតែមានទឹកដមដ៏ផ្អែមធ្វើឱ្យគេចូលចិត្ត ហើយថែមទាំងមានប្រសិទ្ធគុណសំរាប់ព្យាបាលជម្ងឺផ្សេងៗទៀតផងដែរ។ ចាំបាច់កំណាញ់ធ្វើអ្វីគ្រាន់តែពាក្យពីរោះ, ស្មោះត្រង់, រួសរាយរាក់ទាក់ និងពាក្យដាស់តឿនក្រើនរំលឹកមិត្តភ័ក្ត, ដៃគូ, ញាតិមិត្តសាច់សាលោហិតឱ្យខិតខំធ្វើអំពើល្អ, ខិតខំរៀនសូត្រ និងខិតខំធ្វើការងារជាដើមនោះ តែគួរតែនៀយណាយស្អប់ខ្ពើម និងហត់ហេវនូវរាល់ពាក្យសំដីដែលអសារឥតការ,ពាក្យញុះញង់ចាក់ដោតរុកគួន។

ការរស់នៅជាមួយគ្នាគួរតែមានភាពស្មោះនឹងគ្នា,ទន់ភ្លន់ដាក់គ្នា និងជាពិសេសគឺការជួយផ្តល់យោបល់, ដាស់តឿន, ណែនាំអប់រំដោយស្មោះចេញពីទឹកចិត្តដោយសេចក្តីអនុគ្រោះសន្តោសមេត្តាពិតៗ។





ពិតមែនហើយ, ការមានតែអ្នកនិយាយពាក្យអប់រំទន់ភ្លន់តែម្យ៉ាងក៏មិនទាន់គ្រប់គ្រាន់នៅឡើយដែរ លុះត្រាតែមានអ្នកស្តាប់ដោយយកចិត្តទុកដាក់ និងគោរពប្រតិបត្តិតាមទើបមានផលប្រយោជន៍ គឺបានន័យថាមានអ្នកនិយាយដោយល្អហើយមានអ្នកស្តាប់ដោយល្អទៀត។ បើមានតែអ្នកនិយាយដ៏ល្អ តែមិនមានអ្នកស្តាប់ដោយគោរព តើការនិយាយនឹងបានជាប្រយោជន៍អ្វី? ក៏ដូចគ្នាដែរ, បើមានអ្នកស្តាប់ដ៏ចំណាប់តែបែរជាអ្នកនិយាយមិនបានផ្តល់ឱ្យនូវពាក្យមានប្រយោជន៍, ពាក្យសុភាពរាបសា, ពាក្យស្មោះត្រង់នោះក៏នឹងនាំឱ្យមានការឈ្លោះទាស់ទែងខ្វែងគំនិតគ្នា, ចងគំនុំគ្នា និងបើយកទៅអនុវត្តតាម នឹងរឹតតែនាំឱ្យមានភាពអន្តរាយដល់ខ្លួនទៀតផង។ ចំពោះអ្នកស្តាប់, គឺត្រូវមានពេលគិតឱ្យបានល្អិតល្អន់មុននឹងទទួល ឬ ទាត់ចោលនូវគំនិតរបស់អ្នកនិយាយ ព្រោះតាមធម្មតាអ្វីក៏ដោយមិនមែនសុទ្ធតែល្អ ឬក៏អាក្រក់តាំងអស់នោះដែរ។ ដូច្នេះហើយត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់ជាមុនសិនសឹមសំរេចចិត្តជ្រើសជា

ក្រោយទើបមិនមានការខុសឆ្គង។ សូមចាំថា ការស្តាប់ និងការត្រិះរិះដោយល្អរមែងទទួលបាននូវបញ្ញា។ អ្នកនិយាយក៏ត្រូវស្វែងយល់ពីចិត្ត ឬ អារម្មណ៍របស់អ្នកស្តាប់ឱ្យបានច្រើនដែរដើម្បីបង្ការកុំឱ្យឃ្នើសចិត្តអ្នកស្តាប់ (សង់ផ្ទះតំរូវចិត្តអ្នកនៅ) ព្រោះមានពេលខ្លះបើទោះបីយើងនិយាយត្រូវក៏ដោយតែវាខុសពីចំនូលចិត្តអ្នកស្តាប់ ឬ ដោយការប្រើពាក្យសំដីរម៉ោករម៉ាំង ឬក៏កាយវិកាទឹកមុខមិនសមរម្យក៏ជារឿងមួយខូចការអសារប្រយោជន៍ដែរ។

មានចំនុចមួយ ដែលខ្ញុំបានចាំពីទ្រឹស្តីរបស់អ្នកប្រាជ្ញម្នាក់គាត់និយាយថា "សូម្បីពាក្យល្អសោះដែលយើងពោលដាស់តឿនដល់ទៅមួយរយដង តែគេក៏នៅតែមិនព្រមទទួលយក ដោយសារតែពាក្យនោះវាសោះកក្រោះគ្មានជីជាតិ តែគេច្បាស់ជានឹងទទួលយកដោយក្តីរីករាយនូវពាក្យដែលផ្អែមល្ហែមដ៏គ្មានបានប្រយោជន៍បន្តិចសូម្បីមួយម៉ាត់នោះ"។

លោក Dale Carnegie ដែលជាអ្នកមានថ្វីមាត់ដ៏ល្បីល្បាញម្នាក់ត្រូវបានពិភពលោកទទួលស្គាល់ថា ជាបុគ្គល





ផ្តើមក្នុងការប្រើពាក្យសំដីដ៏ស័ក្តសិទ្ធិក្នុងទំនាក់ទំនងជាមួយនឹងមនុស្សផងគ្នា ដែលស្ទើរតែរាល់ពាក្យសំដីដែលគាត់បាននិយាយត្រូវបានគេចូលចិត្តស្តាប់ និងជឿតាមដោយមិនអាចប្រកែកបាននោះគាត់បាននិយាយថា យើងត្រូវរកវិធីណាដើម្បីនិយាយទៅឱ្យអ្នកស្តាប់ឆ្លើយថា ត្រូវ~ត្រូវ ជានិច្ចទាំងគំនិតដែលយើងបាននិយាយបញ្ចុះបញ្ចូលគេគឺត្រូវឱ្យគេមានអារម្មណ៍ថាជាគំនិត ដែលផុសចេញពីការគិតរបស់គេសុទ្ធៗមិនមែនជាការបង្ខិតបង្ខំពីអ្នកនិយាយឱ្យជឿតាមនោះឡើយ។

ក្នុងការទំនាក់ទំនងប្រចាំថ្ងៃ, យើងគ្រប់គ្នាត្រូវការណាស់នូវភាពទន់ភ្លន់ និងភាពជោគជ័យនៅលើគ្រប់ភារកិច្ច។ ហើយលើសពីនេះទៅទៀតគឺយើងចង់ឱ្យការទំនាក់ទំនងរបស់យើងមិនត្រូវបានគេប្រមាថមើលងាយ ឬ ត្រូវបានគេកាត់ផ្តាច់ដោយឧបស័គ្គនានាដែលកើតឡើង ដោយហោចទៅ សូម្បីតែពាក្យសំដីរង្កៀសមិនជាទីពេញចិត្តដ៏តិចតួចចំពោះខ្លួន ឬ ញាតិមិត្តរបស់ខ្លួន។ មែន! វាពិតជាមាន

ប្រយោជន៍ណាស់ ចំពោះការប្រើប្រាស់ពាក្យសំដីឱ្យបានល្អនៅក្នុងកិច្ចការប្រាស្រ័យទាក់ទង (Good Way of the Communications)សំរាប់ជីវិតរស់នៅរាល់ថ្ងៃ។ ក៏ដូចគ្នាដែរ, ការនិយាយស្តីទំនាក់ទំនងគ្នា គឺជាចាំបាច់យើងត្រូវតែប្រើពេល ឬ ឥរិយាបថនៃការស្តាប់ឱ្យបានច្រើនជាជាងការនិយាយ ឬ ដែលអាក្រក់លើសពីនេះទៅទៀតនោះ គឺការដែលចេះតែនិយាយតែមិនចេះស្តាប់មតិរបស់គេវិញដែលវាជាគ្រោះកាចដ៏ក្រៃលែងសំរាប់អ្នកដែលចូលចិត្តនិយាយ។

យើងឃើញហើយជម្លោះទាំងឡាយដែលកើតឡើងពីការនិយាយស្តី គឺភាគច្រើនចេញពីចំណុចដែលនិយាយមិនព្រមចេះស្តាប់គ្នា ឬ ការដែលដណ្តើមគ្នានិយាយដោយមិនបានថ្លឹងថ្លែងត្រិះរិះរកហេតុផលនូវអ្វីដែលភាគីម្ខាងៗលើកយកមកនិយាយនោះឯង។

ត្រង់ចំណុចនេះយើងតែងសង្កេតឃើញនៅក្នុងក្រុមគ្រួសារដែលនៅពេលគេមានការពិគ្រោះយោបល់គ្នា ឬការជជែកវែកញែកគ្នាពីរឿងអ្វីមួយដែលជានិច្ចកាលពួកគេបាន





ខំប្រឹងរកអំណះអំណាងរៀងៗខ្លួនមកបញ្ជាក់ដោយមិនបានគិតពីការស្តាប់យោបល់គ្នានោះឡើយគឺគេខំបញ្ចេញសំឡេងយ៉ាងតឹងសរសៃកដាក់គ្នា។ ទីបំផុតជាលទ្ធផល គឺពួកគេមិនបានផលល្អសូម្បីដ៏តិចតួចឡើយក្រៅតែពីជម្លោះបែកបាក់គ្នាដែលជាអពមង្គលនៅក្នុងគ្រួសារ។ សូមចាំថា នៅក្នុងការនិយាយស្តីអ្វីក៏ដោយគ្មាននរណាម្នាក់សុខចិត្តចុះចាញ់ដោយងាយៗឡើយ ប្រសិនបើយើងមិនព្រមបន្ទូរសំឡេងដើម្បីទទួលយកនូវអ្វីដែលគេផ្តល់ឱ្យយើងនោះ។ មានពេលខ្លះយើងត្រូវបង្ខំចិត្តចុះចាញ់សិនចុះ បើទោះបីជារឿងនោះវាពិតជាត្រូវក៏ដោយ នេះក៏ព្រោះយើងមិនចង់ឈ្នះដោយមានជម្លោះ។ ហើយក៏មានពេលខ្លះនៅពេលដែលយើងព្រមចាញ់ដោយស្រួល គេអាចនឹងគិតសាជាថ្មីហើយដឹងថាខុសព្រមទទួលយកនូវអ្វីដែលត្រូវនោះ ដោយសុទ្ធចិត្តទៀតផង។ សូមជឿចុះថា ផ្លូវដែលល្អគឺត្រូវតែចេះធ្វើជាអ្នកចាញ់ក្នុងខណៈណាដែលគួរចាញ់ ហើយត្រូវតែធ្វើជាអ្នកឈ្នះនៅពេលណាដែលគួរឈ្នះ នៅរាល់ការនិយាយ ឬ ការជជែក

វែកញែក។ ធ្វើដូច្នេះឈ្មោះថាជាអ្នកមានជោគជ័យក្នុងការនិយាយផង និងមិនមានជម្លោះផង។ មួយទៀត,រាល់ការនិយាយត្រូវតែដឹង និងស្គាល់ឱ្យបានច្បាស់ពីកាលៈទេសៈ និងបុគ្គលដែលត្រូវនិយាយជាមួយនោះ ហើយត្រូវតែស្វែងយល់ឱ្យបានល្អិតល្អន់ពីឥរិយាបថ និងបែបបទដែលយើងត្រូវយកមកប្រើដើម្បីឱ្យបានត្រឹមត្រូវជៀសវាងការនិយាយរបស់យើងដែលនាំឱ្យគ្មានប្រយោជន៍ ហើយថែមទាំងនាំឱ្យមានទុក្ខទោសទៀតផង។

ពិតមែនហើយ ! គ្រាន់តែប្រើពាក្យថា **បាទ, ចាស, ជំរាបសួរ, អរគុណ, ជំរាបលា, សូមអភ័យទោសជាដើម** សោះ ហេតុអ្វីយើងចាំបាច់ត្រូវកំណាញ់ហ្ន៎? វាមិនមានការខូចខាតអ្វីទាល់តែសោះ ហើយចុះហេតុអ្វីយើងសំបូរពាក្យគំរោះគំរើយ, ពាក្យរោយរាយឥតការ និងពាក្យបន្តុះបង្អាប់ច្រើនម្ល៉េះ? សូមអ្នកកុំទំលាប់ពាក្យសំដីឥតប្រយោជន៍របស់អ្នកឱ្យកើតមានឡើយ ពីព្រោះថាបើអ្នក **ទំលាប់សំដីនាំឱ្យទំលាប់សកម្មភាព, សកម្មភាពនាំឱ្យទំលាប់ចរិត, ចរិតនាំឱ្យ**



រៀបរៀងដោយ ព្រះមហាមង្គលធម្មោ មត-សុមឿន

**ទំលាប់ប្រពៃណី, ប្រពៃណីនឹងនាំឱ្យបង្កើតជាវាសនារបស់មនុស្ស។** សូមប្រកាន់ឱ្យបានខ្ជាប់ខ្ជួន នូវរាល់ពាក្យសំដីដ៏ប្រកបដោយសីលធម៌។

នៅក្នុងគ្រួសារមួយដែលមានប្ដី, ប្រពន្ធ, កូន, ចៅជាដើមត្រូវតែចេះ**សីលធម៌-សុជីវធម៌**ក្នុងការនិយាយស្ដីឱ្យមានរបៀបរៀបរយល្អ ដឹងខ្ពស់ទាប, ចាស់ក្មេង និងត្រូវតែមានភាពស្មោះត្រង់នឹងពាក្យសំដី(The Polite and Honest Word)។ ប្រធានាធិបតីរបស់សហរដ្ឋអាមេរិកដ៏ល្បីឈ្មោះម្នាក់គឺលោក **Abraham Lincoln** នៅថ្ងៃមួយនៅពេលដែលគាត់កំពុងជិះរទេះជាមួយនឹងសហការីរបស់គាត់ប៉ុន្មាននាក់ទៀត ហើយគាត់បានជួបនឹងអ្នកបោសសំរាមសំអាតទីសាធារណៈម្នាក់ដែលជាបុរសជនជាតិស្បែកខ្មៅ, គេម្នាក់នោះបានជំរាបសួរលោក និងធ្វើគំនាប់ចំពោះលោក,លោក **Lincoln** ក៏បានធ្វើគំនាប់សំដែងនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅតបវិញ។ នៅពេលនោះសហការីគាត់បានសួរថាហេតុអ្វីលោកចាំបាច់គោរពតបទាសកររូបនេះ? គាត់បានឆ្លើយ

តបវិញថា “ព្រោះខ្ញុំមិនចង់ឱ្យមាននរណាម្នាក់ មានសេចក្តីគោរពដ៏ជ្រាលជ្រៅចំពោះខ្ញុំ ជាជាងដែលខ្ញុំត្រូវមានចំពោះគេវិញនោះឡើយ”។

មែនហើយ! ក្នុងភាពជាមេដឹកនាំគេមិនគ្រាន់តែចេះពីវិធីរៀបចំផែនការ, យុទ្ធសាស្ត្រដើម្បីឱ្យបានសំរេចគោលដៅប៉ុណ្ណោះទេ តែគឺត្រូវតែចេះពីវិធីគ្រប់គ្រង និងប្រើមនុស្សផងដែរ នោះគឺបានដល់ការមានភាពប៉ិនប្រសប់ក្នុងការនិយាយស្តីដើម្បីលើកទឹកចិត្ត,ជំរុញទឹកចិត្តឱ្យមានកំលាំងមានឆន្ទៈក្នុងការបំពេញកិច្ចការងារ។ មិនមែនមានត្រឹមតែអំណាច, មានលុយក៏គ្រប់គ្រាន់ក្នុងដំណើរការនៃការដឹកនាំរបស់អង្គភាព, សហគមន៍, អង្គការ ឬ ប្រទេសជាតិឱ្យមានភាពរលូននោះក៏ទេដែរ ចាំបាច់ណាស់ចំពោះការប្រើចិត្តសាស្ត្រត្រជាក់ដោយពាក្យផ្អែមល្ហែម, រួសរាយរាក់ទាក់ និងស្មោះត្រង់ (ក្បួនដឹកនាំបែបទឹកត្រជាក់ត្រីប្រមូលផ្តុំ)។

និយាយដល់ចំនុចនេះ,ប្រហែលជាមានអ្នកខ្លះជំទាស់នឹងខ្ញុំ ព្រោះអាងដល់ពាក្យមួយឃ្លាដែលលើកឡើងថា“មាន





លុយ ឬ អំណាចគឺមានអ្វីៗទាំងអស់”។ ចំពោះបញ្ហានេះខ្ញុំមិនហ៊ានជំទាស់ទេ តែខ្ញុំចង់ឱ្យមិត្តអ្នកអានធ្វើការត្រិះរិះពិចារណាមើលដោយខ្លួនឯងចុះ។ ចំពោះខ្ញុំវិញ, ខ្ញុំធ្លាប់បានឃើញពីចំនុចនេះខ្លះៗដែរ ដូចជានៅក្នុងគ្រួសារមួយដែលមានលុយមានវិទ្យាស្ទីមស្ទែ មានរបស់របរប្រើប្រាស់មិនខ្វះមានមុខមាត់គេទទួលស្គាល់ថាជាអ្នកគ្រាន់បើនៅក្នុងសង្គម តែនៅក្នុងគ្រួសារវិញ បែរជាមិនចុះសំរុងគ្នាជានិច្ចកាល តែងតែនិយាយដាក់គ្នារម៉ោករម៉ាំង មិនចេះស្តាប់ហេតុផលគ្នាទៅវិញទៅមក, ឃើញមុខគ្នាក៏ក្រញ៉ូវចងចិញ្ចើមដាក់គ្នា, និយាយដៀមដាមបញ្ឆិតបញ្ឆៀងដាក់គ្នា, តើសុភមង្គលដ៏រុងរឿងមួយអាចនឹងកើតមានឡើងបានដែរឬទេ? ច្បាស់ជាមិនអាចកើតមានឡើងបានឡើយ ហើយទ្រនំដ៏ស្ដុកស្ដម្ភនេះមុខជានឹងក្លាយទៅជា ស្ថាននរក ដ៏ទុក្ខសោកជាក់ជាមិនខានឡើយ។ នេះក៏ព្រោះមកពីមិនបានអនុវត្តនូវមធ្យោបាយដ៏ល្អក្នុងការទំនាក់ទំនងរវាងគ្នានឹងគ្នា ជាពិសេសគឺការមិនបានដើរតួជាអ្នកនិយាយដ៏ល្អ និងជាអ្នកស្តាប់ដ៏ល្អ (The Good

Speaker and Good Listener) នោះឯង។

នៅក្នុងការនិយាយនៅមុខសាធារណជន, យើងមានបែបផែននៃការនិយាយខុសគ្នាពីការនិយាយជាលក្ខណៈសាមញ្ញជាមួយមិត្តភ័ក្ត ឬ នៅក្នុងគ្រួសារដែរ។ តែទោះជាយ៉ាងណា វិធីដើម្បីធ្វើឱ្យការនិយាយប្រកបដោយជោគជ័យ និងស័ក្តសិទ្ធិគេត្រូវអនុវត្តនូវចំនុចដូចខាងក្រោមនេះ :

-ស្គាល់កាលៈទេសៈនៃការនិយាយ និងបុគ្គលដែលត្រូវនិយាយទៅកាន់នោះ

- និយាយឱ្យបានច្បាស់លាស់ និងចំៗ នូវអ្វីដែលចង់លើកយកមកនិយាយនោះ(កុំបញ្ឆិតបញ្ឆៀងដៀមដាម)

-និយាយអ្វីគឺឱ្យស្តែងចេញពីក្នុងចិត្តពិតៗតាមរយៈការស្តែងទឹកមុខ (រូបារម្មណ៍)

-ផ្តល់នូវស្នាមញញឹម និងកែវភ្នែកដ៏រស់រវើកឱ្យបានច្រើនដងតាមដែលអាចធ្វើទៅបាន

-ប្រើប្រាស់ពាក្យសំដីឱ្យមានទឹកដមផ្អែម, ទន់ភ្លន់ និងសុភាពរាបសា មានសុជីវធម៌



រៀបរៀងដោយ ព្រះមហាមង្គលធម្មោ មត-សុមឿន

-ប្រើកាយវិការប្រកបដោយភាពជឿជាក់ និងទន់ភ្លន់ជានិច្ច(កុំមានការស្ទាក់ស្ទើរ និងអៀនប្រៀន)

-កំណត់ពីពេលវេលា និងវត្ថុបំណងនៃប្រធានបទឱ្យបានសមស្រប និងជាក់លាក់ (ព្រៀងទុកជាមុនឱ្យបានល្អ)

-ចុងបញ្ចប់នៃការនិយាយសូមកុំភ្លេចពាក្យថា "ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់អស់លោកអ្នក និងសូមអភ័យទោសចំពោះកំហុសឆ្គងរបស់ខ្ញុំ ដែលកើតឡើងដោយអចេតនា"។

វាជាការពិតណាស់, ចំណុចទាំងប៉ុន្មានដែលខ្ញុំបាននិយាយមកខាងលើនេះវាជារឿងដ៏សំខាន់ដែលយើងត្រូវតែយកចិត្តទុកដាក់ឱ្យមានប្រសិទ្ធភាពរាល់ខណៈដែលនិយាយស្តីអ្វីមួយ។ តែទោះជាយ៉ាងណាក៏ដោយមនុស្សយើងមិនមាននរណាម្នាក់ ដែលថានិយាយទៅសុទ្ធតែផ្អែមពីរោះ,ទន់ភ្លន់, ល្អឥតខ្ចោះមួយរយភាគរយគ្រប់គ្រានោះឡើយ គឺវាតែងតែមានភាពសោះកក្រោះ ឬ ឆ្គាំឆ្គងខ្លះៗ។ តែអ្វីដែលសំខាន់នោះ គឺយើងត្រូវចេះព្រមល្មមទទួលយកដោយទឹក

ចិត្តអត់ឱនអនុគ្រោះ និងដោយការចេះត្រិះរិះពិចារណាដោយសុភវិនិច្ឆ័យ ទៅលើអ្វីដែលអ្នកដទៃនិយាយមកកាន់យើង។ សូមគិតដល់ប្រយោគមួយឃ្លាថា ស្រមោចជាទូទៅគេតែងតែឃើញស្លាប់នៅក្នុងពាងស្ករ ក៏ដូចគ្នាដែរ ផ្អែមមិនប្រាកដថាសុទ្ធតែជាស្ករ ឬល្អជាទីពេញចិត្តទាំងអស់នោះដែរ គឺជួនកាលក៏អាចមានជាតិពុលបង្កប់លាយជាមួយដែលអាចធ្វើឱ្យមនុស្សស្លាប់បាន ព្រោះតែភាពភ្លើតភ្លើននឹងរសជាតិផ្អែមក៏សឹងមាន។ ឯរសជាតិល្វីងចត់ជូរក៏មិនមែនសុទ្ធតែប្រាកដថាអាក្រក់,ឱនអន់, មិនជាទីពេញចិត្ត ឬក៏ថាគ្មានបានផលប្រយោជន៍ទាំងអស់នោះទេ តែជួនកាលវាក៏ជាឱសថមួយដ៏ស័ក្តសិទ្ធិសំរាប់ព្យាបាលនូវជម្ងឺតម្កាត់ឱ្យជាសះស្បើយបានដែរ។

ដូច្នេះអ្វីក៏ដោយដែលយើងឮ ឬ សូម្បីតែការឃើញរូបរាងថាអាក្រក់ក្តី, មិនពីរោះក្តី, ក៏មិនប្រាកដថាសុទ្ធតែអាក្រក់ទាំងស្រុងគ្មានគុណសម្បត្តិដូចរូបភាពពិតនោះឡើយ តាមពិតអ្វីក៏ដោយ គឺវាមានចំណែកល្អ និងអាក្រក់របស់វា



រៀបរៀងដោយ ព្រះមហាមង្គលធម្មោ មត-សុមឿន

ដោយឡែកពីគ្នា។ ដូច្នេះអ្វីដែលសំខាន់គឺទាមទារឱ្យមនុស្សយើងធ្វើការសំរេចចិត្តជ្រើសរើសទទួលយក ឬថាមិនទទួលយកនូវអ្វីដែលស្តាប់ឮ ឬ មើលឃើញដោយសុភវិនិច្ឆ័យយ៉ាងហ្មត់ចត់ជាទីបំផុតជាមុនសិនដែរ ទើបជាការមិនងាយនឹងភ្លាត់។ ព្រោះដូចដែលយើងតែងឃើញខ្លះហើយ, មនុស្សពូកែបោកគេ ឬ ល្បិចរបស់មនុស្សអាក្រក់ជាច្រើនគឺគេតែងតែប្រើជំនាញដ៏ប៉ិនប្រសប់របស់គេជាមុននោះបានដល់សំដីដ៏ផ្អែមសំលាប់បេះដូងយើងឱ្យស្លាប់ ដោយមិនដឹងខ្លួន ហើយមានតែម្យ៉ាងគឺជឿគេស្លុងងប់អស់ពីចិត្តពីថ្លើម ហើយក្រោយមកក៏ត្រូវគេបោក ឬ ធ្វើទង្វើមិនល្អមកលើខ្លួនយើងដោយយើងមិនមានកំលាំងដើម្បីទប់ទល់នោះឯង(ទឹកឃ្មុំលាយថ្នាំពុល)។

ប្រការដ៏ចាំបាច់, គឺត្រូវតែប្រយ័ត្នចំពោះពាក្យសំដីឱ្យបានម៉ឺងម៉ាត់ទាំងពាក្យពីរោះក្តី, មិនពីរោះក្តីនេះគឺដើម្បីកុំឱ្យថ្លោះធ្លោយនាំឱ្យខូចប្រយោជន៍ ឬ អន្តរាយដល់ខ្លួនបានឱ្យសោះ។

ម្យ៉ាងវិញទៀត,ចំពោះខ្លួនយើងដែលត្រូវនិយាយទៅកាន់គេគឺត្រូវតែព្យាយាមប្រើពាក្យល្អពីរោះផ្អែមល្ហែមឱ្យបានច្រើនជាទីបំផុតដើម្បីជៀសវាងសង្គ្រាមពាក្យសំដី។ សូមធ្វើការស្រមៃដល់កាលដែលយើងនៅតូចៗ,នៅពេលដែលមាននរណាម្នាក់ធ្វើឱ្យយើងខឹង ឬ យើងមិនស្រួលខ្លួន ឬក៏ មិនសប្បាយចិត្តដោយអ្វីមួយ ហើយនៅពេលនោះម្តាយ ឬ បងរបស់យើងមកលួងលោមយើង ដោយពាក្យសំដីទន់ភ្លន់ផ្អែមល្ហែម តើយើងនឹងមានភាពកក់ក្តៅ និងអារម្មណ៍រីករាយក្នុងចិត្តប៉ុណ្ណា? ហើយបើបែរជាឮពាក្យគំរោះគំរើយឬការគំរាមកំហែងវិញនោះ តើយើងនឹងមានអារម្មណ៍ដូចម្តេចទៅវិញ? សូមមិត្តអ្នកអានឆ្លើយដោយខ្លួនឯងមើល!

ខ្ញុំសង្ឃឹមថា រាល់ការនិយាយស្តីទាំងអស់នឹងត្រូវបានរួចផុតពីជម្លោះ និងការចងគំនុំ ប្រសិនបើយើងអនុវត្តនូវចំនុចទាំងប៉ុន្មានខាងលើនេះ។ សូមកុំភ្លេចណា! **Good Speech!** បើយើងភ្លេចវានៅពេលណា បានន័យថាយើងភ្លេចនូវឱកាសជោគជ័យនៃទំនាក់ទំនងរបស់យើងហើយ។





**ខ្ញុំសូមរំលឹកហើយរំលឹកទៀតកុំភ្លេចណា !!!**

**Good Speech!!! សំដីល្អ!!!**

**"មនុស្សល្ងង់យកបេះដូងទុកក្នុងអណ្តាត មនុស្សឆ្លាតយកអណ្តាតទុកក្នុងបេះដូង"**

**៣-<u>លោកត្ថចរិយា</u>** បានសេចក្តីថាការប្រព្រឹត្តធ្វើនូវទង្វើជាប្រយោជន៏ដល់មនុស្សលោក,ផ្តល់នូវសេចក្តីសុខដល់សត្វលោក ឬការធ្វើនូវសេចក្តីល្អដល់មនុស្សទូទៅ ដោយមិនប្រកាន់រើសអើងចំពោះបុគ្គល **(**Fulfilling the good actions for all kinds of living beings**)**។ ធម្មតាមនុស្សយើង គ្មាននរណាម្នាក់ដែលអាចរស់នៅ ដោយកាត់ផ្តាច់ចេញពីគេ ដោយមិនមានទំនាក់ទំនងប្រាស្រ័យកិច្ចការផ្សេងៗបានឡើយ។

នៅទីនេះ, ខ្ញុំសូមបញ្ជាក់ដល់មិត្តអ្នកអានថាពាក្យថា **លោកត្ថចរិយា** បានន័យជាភាសាខ្មែរស្រួលស្តាប់គឺ ការធ្វើល្អដល់គ្នា, ការចេះជួយគ្នា,ការចេះសហការគ្នាក្នុងការងារផ្សេងៗ ឬ ការធ្វើប្រយោជន៍ដោយទូទៅមិនប្រកាន់រើសអើង ឬ ដោយមិនសំឡឹងឃើញការតបស្នងពីបុគ្គលដែលខ្លួនបរិច្ចាគដល់នោះ។

មួយវិញទៀត ពាក្យថាប្រយោជន៍នៅទីនេះបានដល់គុណធម៌ ឬ សេចក្តីល្អពីរយ៉ាងគឺ ការធ្វើល្អសំរាប់ខ្លួនឯងមួយ និង ការធ្វើល្អសំរាប់អ្នកដ៏ទៃ ឬ សំរាប់សង្គមមួយ ឬ អាចនិយាយដល់ការធ្វើប្រយោជន៍ពីរទៀតគឺ ប្រយោជន៍បច្ចុប្បន្នមួយ និង ប្រយោជន៍អនាគត ឬ បរលោកមួយ។ តែនៅក្នុងសៀវភៅនេះ ខ្ញុំអ្នកសរសេរគ្រាន់តែនាំអារម្មណ៍មិត្តអ្នកអាន ឱ្យចាប់អារម្មណ៍ត្រឹមតែចំនុចប្រយោជន៍បច្ចុប្បន្នប៉ុណ្ណោះព្រោះវាមានសារសំខាន់ណាស់សំរាប់ជីវិតប្រចាំថ្ងៃ ហើយក៏ជាផ្លូវដែលនាំឱ្យបានសំរេចប្រយោជន៍អនាគតដ៏ខ្ពង់ខ្ពស់ទៀតផងដែរ។

ជាការពិតណាស់, ថ្វីត្បិតតែមនុស្សយើងម្នាក់ៗរស់នៅដោយឡែកផ្សេងពីគ្នា, មានទីកន្លែងទីទៃពីគ្នា, មានជាតិ





សាសន៍ផ្សេងគ្នា, មានភាសាផ្សេងពីគ្នា, មានទំនៀមទំលាប់ផ្សេងគ្នាឬវប្បធម៌ផ្សេងគ្នា...ក៏ដោយតែអ្វីដែលមនុស្សយើងមានចំនុចដូចគ្នានោះ គឺមានគំនិតចេះស្រឡាញ់ប្រាថ្នាចង់បានសេចក្តីសុខ, ចង់ឱ្យគេគោរពផ្តល់កិត្តិយសឱ្យខ្លួន, ចង់បានឱ្យមានគេឈឺឆ្អាលយកចិត្តទុកដាក់ថែទាំខ្លួន, ចង់មានទំនាក់ទំនងល្អជាមួយនឹងអ្នកដទៃ,មិនចង់បានការរើសអើងពីអ្នកដទៃ, ចង់បានទ្រព្យសម្បត្តិសំបូរសប្បាយចាយមិនខ្វះ និងជាពិសេសនោះគឺទាមទារការផ្តល់នូវក្តីអាណិតស្រឡាញ់រាប់អានដោយស្មោះត្រង់ពីមនុស្សនៅជុំវិញខ្លួនជានិច្ចមិនថាពេលណា ឬ ទីណាឡើយ។ព្រោះតែហេតុនេះហើយទើបបានជាមានមនុស្សមិនតិចនាក់ទេ ដែលបានចំនាយពេលវេលាក្នុងឆាកជីវិតដ៏វែងរបស់ខ្លួនដើម្បីស្វែងរកទ្រព្យសម្បត្តិតាមគ្រប់មធ្យោបាយផ្សេងៗដើម្បីបំពេញនូវសេចក្តីត្រូវការគ្រប់យ៉ាង មិនត្រឹមតែប៉ុណ្ណោះសោត គេក៏បានលៃលកយកទ្រព្យដែលខ្លួនមានទៅជួយចូលរួមចំនែកក្នុងកិច្ចការសង្គមឬសហគមន៍របស់ខ្លួនឬក៏ដល់ជាតិសាសន៍ដទៃទៀត ទាំងនេះ

ដោយសារតែសេចក្តីត្រូវការខាងទ្រព្យសម្បត្តិមិនគ្រប់គ្រាន់ ដែលចាំបាច់តំរូវឱ្យគេចំនាយវិភាគទានដល់សង្គមដើម្បីបាន កិត្តិយសទៀត។

ក៏ដូចគ្នាដែរ, នៅក្នុងអត្ថន័យនៃចំណុច លោកត្ថចរិយា នេះខ្ញុំអ្នកសរសេរសូមលើកយកខ្លឹមសារខ្លះៗ ដើម្បីបញ្ជាក់ ពីបញ្ហាដែលមនុស្សយើងត្រូវតែអនុវត្តចំពោះការរស់នៅក្នុង សង្គមក៏ដូចជានៅលើសកលលោកទាំងមូល។ ដូចដែលមិត្ត អ្នកអានបានដឹងស្រាប់ហើយ, នៅខាងដើមនៃសៀវភៅនេះ ខ្ញុំបានរៀបរាប់ពីបញ្ហា ទាន និង បិយវាចា ដែលខ្ញុំបាន និយាយដល់ចំនុចទំនាក់ទំនងផ្សេងៗនៅក្នុងកិច្ចការប្រចាំថ្ងៃ ដើម្បីធ្វើឱ្យមានភាពរលូនគ្មានទំនាស់ផ្សេងៗ។

ពិតមែនហើយ, បើយើងនិយាយពីសង្គមមួយដែល អាចប្រព្រឹត្តទៅដោយមានភាពរីកចំរើនអភិវឌ្ឍន៍លូតលាស់ ទៅបាននោះ លុះត្រាណាតែសង្គម ឬ ប្រទេសនោះដល់ ព្រមដោយការឯកភាពស្រុះស្រួលគ្នា មិនមានសង្គ្រាមទាំង ផ្ទៃក្នុង និងក្រៅប្រទេសជាពិសេសនោះគឺការជួយជ្រោម





ជ្រែងសហការគ្នារវាងប្រជាជន និងប្រជាជនជាមួយនឹង ថ្នាក់ដឹកនាំគ្រប់លំដាប់ថានានុក្រម ទាំងវិស័យឯកជន និង វិស័យរដ្ឋនោះឯង។ យើងមិនមែនធ្វើការអភិវឌ្ឍប្រទេស មួយទៅបាន ដោយមិនមានការចូលរួមពីបុគ្គលគ្រប់រូបនោះ ឡើយ ព្រោះដោយន័យថាប្រជាពលរដ្ឋគឺជាកំលាំងរបស់រដ្ឋ និងជាចលនករដ៏សំខាន់របស់រដ្ឋ។

ដោយហេតុដូច្នេះហើយ ទើបបានជាទូទៅយើងតែង តែឮពាក្យគេនិយាយថា នៅក្នុងប្រទេសមួយបើមានវត្ថុធាតុ ដើមពុកផុយរលួយ ដែលសំដៅដល់ប្រជាពលរដ្ឋគ្រប់រូប ដែលមិនអើពើដល់ជាតិ ឬ គិតតែកេងចំនេញពីជាតិ ឬ ខ្វះ ធនធានមនុស្ស ឬថាប្រជាជនមិនមានការឯកភាពគ្នាគឺ ច្បាស់ជាដល់នូវក្តីអន្តរាយ រកការអភិវឌ្ឍរីកចំរើនមិនឃើញ ឡើយ។ ត្រង់ចំនុចនេះ គឺខ្ញុំចង់និយាយដល់បញ្ហាជាតិ ទាំងមូល ដែលជានិច្ចកាលទាមទារជាចាំបាច់នូវកំលាំងស្រុះ ស្រួលគ្នាពីប្រជាពលរដ្ឋរបស់ខ្លួន ដើម្បីរួមចំនែកដ៏សំខាន់ ជាមួយរដ្ឋាភិបាល ឬ ថ្នាក់ដឹកនាំ ក៏ដូចជាវិស័យឯកជន

**នានាផងដែរ ក្នុងការជំរុញកង់ចក្រនយោបាយជាតិមួយប្រកបដោយប្រសិទ្ធភាពលើវឌ្ឍនភាពគ្រប់វិស័យ។ ត្រូវតែចាំថា សមាជិកទាំងអស់នៃសង្គមត្រូវតែមានកាតព្វកិច្ចជាចាំបាច់រៀងៗខ្លួន នោះគឺបានដល់ការចូលរួមចំនែកដ៏ខាន់ដើម្បីធ្វើឱ្យកង់ចក្រនៃសង្គមអភិវឌ្ឍទៅមុខបាន ដោយតំរូវឱ្យសមាជិកនីមួយៗ ធ្វើការលះបង់រួមចំនែកវិភាគទាន ទាំងផ្នែកសម្ភារៈថវិកា និងកំលាំងកាយចិត្តយ៉ាងសកម្មបំផុត។**

ក៏ដូចគ្នាដែរ,នៅក្នុងជីវភាពគ្រួសារមួយដើម្បីរៀបចំទិសដៅមួយឆ្ពោះទៅរកត្រើយសុភមង្គលដ៏ជាក់លាក់ ក៏មិនខុសពីការរៀបចំដំនើរការនយោបាយជាតិប៉ុន្មានទេ គឺតំរូវឱ្យមានកត្តាចូលរួមចំនែកដ៏សំខាន់ពីបុគ្គលនីមួយៗ នៃសមាជិកក្នុងគ្រួសារទាំងមូលផងដែរ។ ពិតមែន! មិនមែនគ្រាន់តែមានប្តី-ប្រពន្ធ, កូនក៏ជាការគ្រប់គ្រាន់នោះឡើយ អ្វីដែលសំខាន់នោះគឺការចេះរៀបចំដំណើរការនៃសង្គមគ្រួសារឱ្យមានសភាពរលូនទៅមុខជានិច្ច។ តើការរៀបចំគ្រួសារឱ្យមានភាពរលូនទៅមុខនេះបានន័យដូចម្តេច? គឺវាបានដល់ការធ្វើអ្វីៗសព្វ





យ៉ាងដើម្បីគ្នាទៅវិញទៅមក ដោយមិនគិតពីផលប្រយោជន៍ពីគ្នាអ្វីទាំងអស់( លះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីគ្រួសាទាំងមូលដោយទឹកចិត្តស្មោះត្រង់) ។ខ្ញុំសូមលើកយកឧទាហរណ៍មួយដែលទាក់ទងទៅនឹងជីវប្រវត្តិពិត នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង( **ព្រះសមណគោតម**) ដែលជាតួយ៉ាងដ៏សំខាន់ ក្នុងកិច្ចការបំពេញប្រយោជន៍ទាំងសំរាប់ខ្លួនព្រះអង្គផ្ទាល់ និងដើម្បីមនុស្សសត្វដទៃទូទៅផង។ គ្រប់ជាតិកំណើតរបស់ព្រះអង្គគឺព្រះអង្គតែងតែខិតខំព្យាយាមយ៉ាងតឹងរឹងជាទីបំផុតក្នុងការធ្វើសេចក្តីល្អ ឬប្រយោជន៍( បារមី ឬ បុណ្យ) ដោយមិនបានលះបង់អត្តភាពឱ្យនៅទទេស្ងួនឲ្យចាកប្រយោជន៍ឡើយ។ មិនតែប៉ុណ្ណោះទៀតសោតក្នុងកំណើតចុងក្រោយរបស់ព្រះអង្គៗបានលះបង់ដ៏អស្ចារ្យ ដែលគ្មានបុគ្គលណាមួយក្នុងលោកធ្វើដូចព្រះអង្គបាន គឺថាព្រះអង្គទ្រង់បានលះបង់សម្បត្តិជាស្តេចចក្រ, ភរិយាដ៏ប្រកបដោយលក្ខណៈល្អស្រស់សោភាទន់ភ្លន់, បុត្រជាទីស្រឡាញ់គ្មានអ្វីប្រៀប, ញាតិមិត្តវង្សត្រកូល និងបរិវារស្រីស្នំដ៏មិនចេះខ្វះ ដើម្បីចេញសាងព្រះផ្នួសព្រោះព្រះអង្គសំឡឹងឃើញប្រយោជន៍ដ៏ធំធេង សំរាប់ជួយស្រោច

ស្រង់សព្វសត្វទាំងឡាយឱ្យចេញចាកទុក្ខសោកក្នុងលោកនេះ និង ដើម្បីបានដល់ព្រះនិព្វាន ជាទីក្សេមក្សាន្តផុតទុក្ខព្រួយទាំងពួង។ លើសពីនេះទៅទៀត, ដោយសារទឹកព្រះទ័យដ៏ធំធេង និងដ៏សែនបរិសុទ្ធប្រកបដោយមេត្តា ករុណាគ្មានទីបំផុតចំពោះសព្វសត្វនោះ នៅពេលព្រះអង្គបានត្រាស់ហើយព្រះអង្គទ្រង់បានលះបង់កំលាំងកាយចិត្ត ដោយមិននឿយហត់ក្នុងការយាងទៅតាមស្រុក, ភូមិ, និគមជនបទ,ខេត្ត,ខ័ណ្ឌបុរី ដើម្បីសំដែងព្រះធម៌ប្រោសដល់សព្វសត្វឱ្យលុះក្នុងមគ្គផល-កុសល-បុណ្យ-ទានផ្សេងៗ ទៅតាមករិតឧបនិស្ស័យរបស់សត្វអស់រយៈពេល ៤៥ ព្រះវស្សា រហូតដល់ទីបំផុតនៃព្រះជីពជន្មាយុរបស់ព្រះអង្គៗបានខិតខំព្យាយាមណែនាំពន្យល់ដល់បរិស័ទ ឱ្យប្រឹងប្រែងធ្វើបុណ្យសន្សំកុសលដើម្បីបង្ការទុក (សង្ខារមិនទៀង) ដោយមានព្រះពុទ្ធដីកាថា "ម្នាលអ្នកទាំងឡាយចូរកុំប្រមាទក្នុងសង្ខារ" បើទោះបីជាព្រះអង្គកំពុងមានព្រះរោគាពាធដ៏ធ្ងន់ធ្ងរទៀបនឹងផុតដង្ហើមចុងក្រោយក៏ដោយចុះនេះគឺជារឿងមួយគួរឱ្យចងចាំទុកក្នុងចិត្តរបស់យើងគ្រប់គ្នា។

ម្យ៉ាងទៀត,ខ្ញុំអាចនិយាយបានថាការរស់នៅជាមួយគ្នាជា





គ្រួសារមិនមែនប៉ះដៃយកដៃប៉ះជើងយកជើង ឬ យកកំហឹងមកទល់កំហល់នោះក៏ទេដែរ គឺត្រូវតែមានការយោគយល់គ្នាជានិច្ចចេះអធ្យាស្រ័យឱ្យគ្នា ចេះអត់ធ្មត់រាល់កិច្ចការ ឬ ពាក្យសំដីរឿងរ៉ាវផ្សេងៗ។ ជាធម្មតាទេការរស់នៅជាមួយគ្នា ដែលមានមនុស្សចាប់ពីពីរនាក់ឡើងទៅ មិនដែលមាននរណាដែលមិនចេះរកាំរកូសទាស់ប្រកែកគ្នាសោះនោះទេ តែគឺគេត្រូវតែជៀសវាងការឈ្លោះគ្នានោះឱ្យបានច្រើនជាទីបំផុត តាមដែលអាចធ្វើទៅបានដោយមានពេលខ្លះ គឺត្រូវព្យាយាមដើរចេញឱ្យឆ្ងាយមិនតមាត់តសំដី។ ត្រូវចាំថា ការដែលប្រឈមមុខដាក់គ្នាពុំមែនជាមធ្យោបាយដ៏ល្អក្នុងការដោះស្រាយបញ្ហានោះឡើយ តែគឺមានតែការព្យាយាមរកដំណោះស្រាយដោយសន្តិវិធីប៉ុណ្ណោះ ទើបរកច្រកចេញពីជម្លោះបាន ដែលនេះគេហៅថាការលះបង់ប្រយោជន៍តិចដើម្បីបានប្រយោជន៍ច្រើន(ស្អប់ឈ្លោះទើបបានសុខ)។

ពិតមែនហើយ! ការស្រឡាញ់គ្នាដើម្បីរួមរស់ជាគូមេត្រីភរិយា-ស្វាមី ឬ ហៅម្យ៉ាងទៀតថា គូអនាគតមួយរយឆ្នាំនោះតំរូវឱ្យមានលក្ខខ័ណ្ឌបួនយ៉ាងគឺ : **ការលះបង់** (Devotion)

**មួយ,ការស្មោះត្រង់**(Loyalty)**មួយ, ការផ្តល់កិត្តិយស**(Honour)**មួយ និងការផ្តល់សុភមង្គល ឬភាពរុងរឿងសុខដុម**(Happiness or Prosperity)**មួយៗ** គ្រួសារប្តី-ប្រពន្ធណាដែលបានប្រកបដោយចំនុចទាំងបួននេះ ទើបអាចស្វែងរកសេចក្តីសុខសាន្តសុភមង្គលពិតប្រាកដបាន បើមិនដូច្នោះទេ ពុំអាចទទួលបាននូវចំនុចទឹកឃ្មុំនៃគ្រួសារបានឡើយ ។

ជាធម្មតា, ការស្រឡាញ់តែងតែមានជានិច្ចសំរាប់មនុស្សយើងគ្រប់គ្នា ជាពិសេសគឺចំពោះមនុស្សដែលមានភេទផ្ទុយគ្នា (ប្រុស និងស្រី) តែសេចក្តីស្រឡាញ់នឹងសូន្យទៅវិញដោយឆាប់រហ័សជាទីបំផុត ប្រសិនបើការស្រឡាញ់នោះមិនប្រកបដោយការហ៊ានលះបង់ពិតប្រាកដពីក្នុងចិត្ត, ការស្មោះត្រង់ចំពោះគ្នា, ការគោរពផ្តល់កិត្តិយសឱ្យគ្នា និង ការកំណត់ពិតប្រាកដថានឹងអាចស្វែងរកនូវសេចក្តីសុខសុភមង្គល ឬ ភាពរុងរឿងឱ្យគ្នាបាននោះ។ ដូច្នេះគូស្នេហ៍ទាំងឡាយគួរតែចងចាំនូវ រូបមន្តចំណងទាំងបួនប្រការនេះ ឱ្យបានជានិច្ចដើម្បីរឹតចំណងស្នេហ៍ និងកំដៅស្នេហ៍ឱ្យនៅឧណ្ហរហូត កុំឱ្យសាបសូន្យទៅតាមការប្រែប្រួលនៃ





រូបរាងកាយដែលកាន់តែចាស់ជ្រេទៅមុខមិនដាច់នោះអី ។ សូមឱ្យការស្រឡាញ់ស្ថិតនៅក្នុងចិត្ត តែកុំឱ្យការស្រឡាញ់ស្ថិតនៅតែក្នុងរូបសម្ផស្សតែម្យ៉ាងឱ្យសោះ ព្រោះរូបរាងកាយមិនអាចស្ថិតនៅគង់វង្សអមតៈឡើយ ។

ការដែលប្រកាន់យកតែខាងត្រូវ សំរាប់ខ្លួនឯងដោយដាច់អហង្កាក៏ពុំមែនជាការល្អឡើយ គឺត្រូវតែទុកឱ្យអ្នកម្ខាងទៀតគេត្រូវខ្លះផង។ ត្រង់ចំនុចនេះបានន័យថា មនុស្សយើងត្រូវតែបែងចែករវាងហេតុ និងផលឱ្យបានច្បាស់លាស់ និងម៉ឺងម៉ាត់ជាទីបំផុត ហើយក៏មិនត្រូវប្រកាន់ចរិតច្រឡើសបើស មិនត្រូវទំនងឡើយ ។ ត្រូវចាំថាយើងមិនមែនត្រឹមតែមាន **ធមិលោកត្ថចរិយា** ដែលមានន័យថាការ ប្រព្រឹត្តជាប្រយោជន៏ដល់មនុស្សលោកទូទៅដោយត្រឹមតែការផ្តល់ប្រយោជន៏មានការឱ្យវត្ថុសម្ភារៈផ្សេងៗ ជាដើមនោះទេ តែគឺយើងត្រូវឱ្យសេចក្តីសុខស្ងប់ និងការផ្តល់កំលាំងចិត្តដល់គ្នាផងដែរ ។

ទន្ទឹមនិងនេះដែរ, ការធ្វើប្រយោជន៏ចំពោះគ្នានឹងគ្នា, ការធ្វើប្រយោជន៏ដល់មនុស្សទូទៅ និងការចេះផ្តល់នូវសេចក្តីសុខ

ចំរើន ឬ ការចេះជួយជ្រោមជ្រែងទំនុកបំរុង ជាកាតព្វកិច្ចរបស់មនុស្សគ្រប់គ្នាដែលត្រូវធ្វើជាប្រចាំក្នុងជីវិត ។ មនុស្សយើងមិនត្រូវគ្រាន់តែសេចក្តីត្រូវការ ឬក៏ដោយសារតែប្រយោជន៍របស់ខ្លួនឯងរហូតហ៊ានធ្វើឱ្យបាត់បង់ប្រយោជន៍ ឬ សេចក្តីសុខសាន្តរបស់អ្នកដទៃនោះទេ គឺត្រូវតែរក្សាឱ្យបានទាំងប្រយោជន៍របស់ខ្លួន និងប្រយោជន៍របស់អ្នកដទៃ ។ តាមផ្លូវព្រះពុទ្ធសាសនាបុគ្គលណាដែលកាត់ផ្តាច់នូវប្រយោជន៍ពីរគឺប្រយោជន៍ផ្ទាល់ខ្លួនមួយ និងប្រយោជន៍អ្នកដទៃមួយ ឬ ដែលមិនបានបំពេញនូវ **លោកត្ថចរិយាធម៌** នេះបុគ្គលនោះឈ្មោះថាជាមនុស្សអាស្រូវអសោចិ៏កេរ្តិ៏ (**អត្តត្ថញ្ញា អសុចី មនុស្សា**) ហើយថែមទាំងឈ្មោះថាជាបុគ្គលពាលទៀតផង ។

ការរស់នៅក្នុងសង្គម មនុស្សត្រូវតែចេះធ្វើប្រយោជន៍ឱ្យគ្នា, ចេះជួយគ្នា, ចេះយកអាសាគ្នា ទាំងចំពោះញាតិមិត្តខ្លួនឯង និងចំពោះមនុស្សទូទៅ ក៏ដូចជាចំពោះសង្គមជាតិទូទៅផងដែរ ។ មនុស្សយើងត្រូវតែចៀសឱ្យបាន នូវភាពជាមនុស្សដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ឬហៅថា អត្តទត្ថបុគ្គល (Egotism)ហើយ





យើងត្រូវតែសាងភាពជាបុគ្គលដែលចេះគិតគូរដល់ប្រយោជន៍អ្នកដទៃដែលហៅថា បរទត្ថបុគ្គល (Altruism)ឱ្យបាន ។

នៅក្នុងសង្គម យើងត្រូវជួយឈឺឆ្អាលយកចិត្តទុកដាក់ឱ្យបានខ្ពស់ ចំពោះកិច្ចការងារសំរាប់ខ្លួនឯង, សំរាប់មនុស្សដែលខ្លួនស្រឡាញ់, សំរាប់សង្គមដែលខ្លួនរស់នៅ និងជាពិសេសគឺដើម្បីបុព្វហេតុសង្គមជាតិទាំងមូល ។

ចំពោះសង្គមយើងត្រូវតែគិតថាគឺជាផ្ទះដែលស្នាក់នៅរាល់ថ្ងៃដែលយើងសក្តិសមជាទីបំផុតដើម្បីបោសសំអាតថែទាំ និងធ្វើការជួសជុលប៉ះប៉ុនកុំឱ្យខាតខូចបាត់បង់អសារ ។ យើងមិនត្រូវមិនអើពើ បំភ្លេចជាតិចោល ដោយមិនគិតពីការបាត់បង់ទឹកដី,ការជ្រៀតជ្រែកពីប្រទេសដទៃ និងមិនគិតពីការចូលរួមចំណែកស្ថាបនាកសាងជាតិឬថាគិតតែពីយករួចខ្លួននោះឡើយ ព្រោះថាបើជាតិស្លាប់យើងក៏ត្រូវស្លាប់ បើជាតិក្រយើងក៏ក្រ បើជាតិថោកទាបយើងក៏ថោកទាបតាមដែរ ។

ហេដ្ឋារចនាសំណង់, សមិទ្ធផលនានា, កិច្ចការ ឬ សេចក្តីត្រូវការដែលជាតិត្រូវការ, ជាតិខ្វះខាតយើងដែលជាប្រជាពលរដ្ឋ

ជាកំលាំងចលករដ៏សំខាន់របស់ជាតិ ត្រូវតែមានស្មារតីទទួលខុសត្រូវចំពោះជាតិ ដោយចូលរួមលះបង់ធ្វើវិភាគទានទាំងកំលាំងកាយចិត្តដើម្បីបុព្វហេតុបំរើជាតិមាតុភូមិ។ យើងត្រូវតែរួបរួមសាមគ្គីគ្នា, ចងបាច់គ្នាជាធ្លុងមួយ ក្នុងការបំពេញកាតព្វកិច្ចជាមនុស្សល្អសំរាប់ជាតិ ក៏ដូចជាដើម្បីមនុស្សទាំងឡាយដែលជាមិត្តរួមជាតិជាមួយគ្នា។

ព្រះពុទ្ធសាសនាបានបង្រៀនឱ្យមនុស្សចេះរួបរួមគ្នា, ចេះស្រឡាញ់គ្នា, ចេះជួយគ្នាគ្រប់ពេលវេលា និងទីកន្លែង នោះគឺបានដល់ការប្រព្រឹត្តឱ្យជាប្រយោជន៏ដល់គ្នានិងគ្នា (**លោកត្ថចរិយា**) នោះឯង ដែលនេះជាសង្គហធមិដ៏សំខាន់សំរាប់ធ្វើការទាក់ទងនៅក្នុងសង្គម។ ដូចដែលយើងបានដឹងហើយនៅបណ្តាប្រទេសដែលគោរពកាន់ព្រះពុទ្ធសាសនា គឺភាគច្រើនជាអ្នកដែលមានសេចក្តីអាណិតរាប់អានស្រឡាញ់គ្នា និងចេះជួយគ្នា ជាក់ស្តែងដូចជាប្រទេសកម្ពុជាយើងដែលស្ទើរតែរាល់សមិទ្ធផលសាធារណៈ ឬ សំណង់សាធារណៈផ្សេងៗ គឺប្រជាពលរដ្ឋយើងតែងតែបាននាំគ្នាយ៉ាងសស្រាក់សស្រាំ ដើម្បីចូលរួមលះបង់ទាំងធនធានទាំង





កំលាំងកាយចិត្ត ដែលខ្លួនមានកសាងទៅតាមលទ្ធភាពដែលខ្លួនអាចធ្វើទៅបាន ដោយមិនគិតពីការខាតបង់លុយកាក់ថវិកា, វត្ថុសម្ភារៈ,ពេលវេលានិងកំលាំងកាយចិត្តឡើយ។ ចំនុចទាំងអស់នេះសបញ្ជាក់ឱ្យឃើញថា ព្រះពុទ្ធសាសនាបានចូលរួមចំណែកច្រើនណាស់នៅក្នុងវិស័យសង្គម គឺចូលរួមចំណែកនៅត្រង់ការអប់រំឱ្យមនុស្សចេះស្រឡាញ់សាមគ្គីគ្នា និងការលះបង់នូវចំណង់អត្តទត្ថៈ ហើយព្យាយាមបំពេញនូវប្រយោជន៏ទាំងពីរឱ្យកើតមានឡើងនោះឯង។

មែន! បើនិយាយពីប្រទេសកម្ពុជាវិញ ជាប្រទេសដែលមានចំនួនប្រជាជនក្រីក្រច្រើន តែបើនិយាយពីទឹកចិត្តសាមគ្គីសហការគ្នា ឬចិត្តជាអ្នកបុណ្យវិញគឺកម្ពុជាមិនបានក្រដោយពិត។ ដោយហេតុថា ប្រជាជនកម្ពុជាជាអ្នកគោរពកាន់ព្រះពុទ្ធសាសនា ហើយព្រះពុទ្ធសាសនាជាសាសនា ដែលប្រៀនប្រដៅបរិស័ទឱ្យចេះធ្វើបុណ្យ, ចេះធ្វើសេចក្តីល្អ, ចេះចែករំលែក និងចេះជួយគ្នាដែលមិនតំរូវឱ្យប្រកាន់រើសអើងគ្នា។ ព្រោះហេតុដូច្នោះបានជាយើងឃើញហើយសព្វថ្ងៃនេះ សមិទ្ធផលនានាដែលមានដ៏ច្រើន

សន្ទឹកសន្ធាប់នៅក្នុងសង្គមគឺភាគច្រើនដូចជាផ្លូវថ្នល់,ស្ពាន,សាលារៀន,មន្ទីរពេទ្យ,អណ្តូងទឹក,ស្រះទឹក,កុដិ,សាលា,ព្រះវិហារនៃវត្តអារាមជាដើម ត្រូវបានបដិសន្ធិឡើងតាមរយៈព្រះពុទ្ធសាសនា (ការរួមចំណែកជ្រះថ្លារបស់ពុទ្ធបរិស័ទ) នោះឯង។

ទន្ទឹមនឹងនេះដែរ ក៏ព្រោះដោយសារពុទ្ធបរិស័ទមានការជឿជាក់លើបុណ្យ,បាប,គុណ,ទោស កម្ម និងផលរបស់កម្ម និងដោយសារតែ ការជឿលើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលប្រកបដោយហេតុផលជាក់ស្តែង និងប្រព្រឹត្តទៅទទួលបានផលប្រយោជន៍ដ៏ច្រើនទាំងសំរាប់បច្ចុប្បន្នជាតិ និងអនាគតជាតិ ជាពិសេសនោះគឺនៅត្រង់ចំនុចសង្គហធម៌ទី៣គឺ **លោកត្ថចរិយា** ដែលមានន័យថាការធ្វើប្រយោជន៍ដល់មនុស្សទូទៅ ឬ ការធ្វើប្រយោជន៍ដល់សាធារណៈជននោះឯង។

វាពិតជារឿងមួយដ៏គួរឱ្យសោកស្តាយ ប្រសិនបើក្នុងមួយជីវិតមិនបានសាងសេចក្តីល្អ ឬ សាងប្រយោជន៍ទុកសំរាប់ខ្លួនឯងសំរាប់សង្គម និងសំរាប់មនុស្សដែលខ្លួនស្រឡាញ់ពេញចិត្ត។ មនុស្សយើងមិនគួរព្រោះតែសេចក្តីសប្បាយភ្លើតភ្លើន ឬ ព្រោះតែ





ភាពចង់បានពេករហូតភ្លេចគិតគូរដល់ការកសាងសេចក្តីល្អ ឬផលប្រយោជន៍ ហើយរហូតដល់ហ៊ានធ្វើទង្វើអាក្រក់ផ្សេងៗ ឬ រឹតតែវិសេសជាងនេះទៅទៀត គឺមិនត្រូវធ្វេសប្រហែសប្រមាទក្នុងអាយុជីវិត ដោយអាងថាខ្លួននៅក្មេងពេក ខ្លួនមិនមានរោគខ្លួនមានទ្រព្យសម្បត្តិច្រើន ខ្លួនមានញាតិច្រើន ឬ ខ្លួនមានបញ្ញាច្រើននោះឡើយ។ ថ្ងៃនិងយប់រមែងអស់ទៅជាមួយនឹងអាយុជីវិតរបស់យើង ដោយមិនមានខ្លឹមសារអ្វីទាំងអស់ ព្រោះតែយើងមានសេចក្តីធ្វេសប្រហែស។ សូមចាំថា ពេលវេលារមែងមិនរង់ចាំបុគ្គលឡើយ គឺមានតែបុគ្គលទេដែលរង់ចាំពេលវេលា នោះហើយជាវេលាដ៏សែនយូរនៅពេលដែលយើងទន្ទឹងរង់ចាំដោយមិនធ្វើអ្វីដូច្នេះ។

ការមិនបានបំពេញសេចក្តីល្អ ឬប្រយោជន៍ឈ្មោះថាបុគ្គលមានសេចក្តីប្រមាទឬឈ្មោះថាមានសេចក្តីខ្ជិលច្រអូស (អលសោ) ដែលភាសាអង់គ្លេសហៅថា (laziness) ដែលវាជាចំនុចមួយធ្វើឱ្យវិនាសសាបសូន្យចាកគុណទាំងពួង។ នៅក្នុងដំណើរជីវិតប្រចាំថ្ងៃមនុស្សយើងគ្រប់គ្នាទាំងអស់មិនត្រូវខ្ជិលច្រអូស, ដំអក់

ទ្រមក់, លង់លក់, អែនអន, បណ្តែតបណ្តោយ មិនខ្នះខ្នែងក្រវើនក្រតើនឡើយគឺចាំបាច់ត្រូវតែខិឃ្មាត, ឧស្សាហ៍, ឱហាត, សង្វាត, ស្រវាស្រទេញបំពេញគុណប្រយោជន៍តិចច្រើនដោយហោច កុំឱ្យសោះទទេឥតការ (កុំស្លាប់ដូចពស់ និងកុំរស់ដូចសត្វកង្កែប)។ ក្នុងវ័យសិក្សា ត្រូវតែប្រឹងប្រែងរៀនសូត្រសព្វមុខវិជ្ជា-ជំនាញផ្សេងៗ ដោយស្វាហាប់តស៊ូប្តូរផ្តាច់មិនខ្លាចនឿយហត់អស់កំលាំង និងពុះពារគ្រប់ឧបស័គ្គ មិនរាថយដើម្បីបំពេញឱ្យបាននូវជំនាញវិជ្ជាការពិតប្រាកដមួយសំរាប់ជីវិតរស់នៅក៏ដូចជាការលើកកំពស់ដល់តំលៃកិត្តិយសរស់នៅរបស់ខ្លួន, របស់គ្រួសារ និងរបស់សង្គមផងដែរ។

ការមិនខ្ជិលច្រអូសក្នុងការប្រកបមុខរបររកស៊ី,ធ្វើកិច្ចការងារផ្សេងៗ, ធ្វើការពណិជ្ជកម្ម,ការងារហត្ថកម្ម,ការងារឧស្សាហកម្ម និងការងារកសិកម្មជាដើម ជាហេតុនាំមកនូវទ្រព្យសម្បត្តិទាំងអស់នេះក៏ឈ្មោះថាបានធ្វើប្រយោជន៍ដែរ ព្រោះបានធ្វើឱ្យកើតមានសេចក្តីចំរើនតាមផ្លូវសុចរិតយុត្តិធម៌ទៀងត្រង់។

ដោយសេចក្តីថាមនុស្សយើងជាអ្នកចេះសាងអនាគត,ចេះ





រៀបចំអនាគត, ចេះរៀបចំជោគវាសនា និងចេះធ្វើជាម្ចាស់ព្រេងសំនាងរបស់ខ្លួន ដូច្នេះហើយមិនត្រូវទុកបណ្តោយជីវិតខ្លួនឱ្យទៅតាមជំនោនៃវាសនាឡើយ គ្មានទេវតាណាជួយយើង, នាំទ្រព្យសម្បត្តិឬយសស័ក្តិឱ្យយើង ដោយយើងមិនបានខិតខំប្រឹងប្រែងធ្វើទទាំងដែលការងារទាំងឡាយនោះមានសភាពលំបាកផង និងជាការងារប្រាសចាកទោសផង។ សូមចាំថា ជីវិតគឺជាការតស៊ូ, ឧស្សាហ៍ប្រឹងប្រែងធ្វើការងារមិនដាក់ធុរៈ, សិក្សារៀនសូត្រ និងរីករាយ។

លើសពីនេះទៅទៀត ក្នុងការរស់នៅដើម្បីឱ្យជីវិតកាន់តែមានភាពស្រស់ថ្លាបំព្រងជានិច្ចនោះ គឺមនុស្សយើងម្នាក់ៗមិនមែនគ្រាន់តែដើម្បីបានសំរេចអ្វីតាមបំណងខ្លួន ឬក៏ ដើម្បីតែបានប្រយោជន៍ផ្ទាល់ខ្លួន ឬថាដើម្បីបក្សពួករបស់ខ្លួនហើយក៏ហ៊ានទៅប្រព្រឹត្តធ្វើអំពើអមនុស្សធម៌,ព្រៃផ្សៃយង់ឃ្នង់,កិបកេងលួចលាក់ក្បត់កំបាំង,ស៊ីសំណូកសូកប៉ាន់,លំអៀង,អយុត្តិធម៌ចំពោះអ្នកដទៃនោះទេ គឺត្រូវតែស្មោះត្រង់ចំពោះខ្លួនឯង,ចំពោះកិច្ចការងារ និងចំពោះសង្គម ដោយប្រកាន់យកការស្មោះត្រង់, ភាពស្អាតស្អំជា

សេចក្ដីថ្លៃថ្នូរជានិច្ច។ សូមកុំគិតថា ដោយសារតែភាពស្មោះត្រង់, ភាពស្អាតស្អំ ភាពយុត្តិធម៌ ទើបធ្វើឱ្យយើងក្រ ឬគេមើលងាយឱ្យសោះ ព្រោះដោយសារតែគំនិតដូច្នេះហើយ ទើបបានជាមនុស្សតែងតែមានការគាបសង្កត់កេងប្រវ័ញ្ចនឹងគ្នា នៅក្នុងសង្គមមិនចេះចប់មិនចេះហើយធ្វើឱ្យសង្គ្រាមនៃចិត្តចងគំនុំគ្នានៅតែមានផ្សេងជាប់មិនដាច់។ សន្តិភាពមិនមែនបានមកពីណាក្រៅខ្លួនយើង ឬបានពីការបួងសួងបន់ស្រន់អារក្សទេវតា ឬ ព្រះអាទិទេពនោះទេ តែគឺបានពីខ្លួនយើងម្នាក់ៗ ដែលសាងភាពសុខស្ងប់ មិនចងគំនុំអាឃាតបៀតបៀនគ្នា និងចេះធ្វើល្អដាក់គ្នាទៅវិញទៅមកនោះឯង។

មួយវិញទៀត មនុស្សយើងម្នាក់ៗបើមិនបានធ្វើល្អដល់ខ្លួនឯង,ដល់អ្នកដទៃ ឬដល់សង្គមទេ ក៏មិនត្រូវធ្វើអាក្រក់ឬធ្វើឱ្យខាតខូចប្រយោជន៍-វិនាសហិនហោចដល់អ្នកដទៃ ឬ ដល់សង្គមឡើយ។ ក៏ដូចជាពាក្យស្លោកបុរាណថា "បើមិនបានជួយគេឱ្យបានសេចក្ដីសុខទេ ក៏មិនត្រូវបំផ្លាញសេចក្ដីសុខរបស់គេដែរ ឬថាបើមិនបានធ្វើឱ្យគេស្រឡាញ់ទេ ក៏មិនត្រូវធ្វើឱ្យគេស្អប់ឡើយ"។





ខ្ញុំអ្នកសរសេរមានការជឿថា នៅក្នុងសង្គមរស់នៅជាក់ស្ដែង បើមនុស្សគ្រប់គ្នាបានយកចិត្តទុកដាក់ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវធម៌ដែលខ្ញុំបានរៀបរាប់មកខាងលើនេះ ដោយចិត្តស្មោះស្ម័គ្រ នោះសេចក្ដីសុខសុភមង្គល ពិតជានឹងអាចកើតមានឡើងមិនខានឡើយ។

ទន្ទឹមនឹងនេះដែរ, ការជៀសឱ្យឆ្ងាយពីអំពើពាលាអាវ៉ាសែ ឬ ល្បែងហិនហោចទាំងឡាយមានដូចជា ការលេងស្រីញី, ប្រុសឈ្មោល,ក្បត់ប្រពន្ធ-ប្ដី ឬ មានលួចលាក់សាហាយស្មន់ជាមួយកូនចៅប្រពន្ធ-ប្ដីអ្នកដទៃក្បត់ប្រពៃណី ឬក៏ទៅប្រព្រឹត្តពេស្យាកម្មជាដើមមួយ,ការដើរផឹកស៊ីគ្រឿងស្រវឹង,ញៀនប៉ាឡៃជាមួយនឹងបក្សពួកបនភឿន ដោយមិនគិតធ្វើកិច្ចការងារផ្សេងៗមួយ, ការលេងល្បែងស៊ីសងទាំងឡាយមួយ, និងការសេពគប់សមាគមជាមួយមនុស្សមិនល្អទាំងឡាយជាមិត្តមួយ ក៏ជាបញ្ហាដ៏សំខាន់ខ្លាំងណាស់ដែរសំរាប់ជីវិតរស់នៅប្រចាំថ្ងៃដើម្បីសំរេចបាននូវ សេចក្ដីសុខចំរើនសុភមង្គលរុងរឿងពិតប្រាកដ។

**"ស្រឡាញ់ការអាន គឺស្រឡាញ់បញ្ញា"**

**៤.សមានត្តតា:**បានសេចក្ដីជាភាសាខ្មែរថាការប្រព្រឹត្តខ្លួនដោយស្មើ,ការប្រព្រឹត្តខ្លួនដោយមិនរើសអើងឆ្មើងឆ្មៃ, ការមិនប្រកាន់ខ្លួន(Humility)ឬ ការមិនលើកតំកើងខ្លួន ឬក៏ធ្វើឫកពាក្រអឺតក្រទម ព្រោះហេតុតែទ្រព្យសម្បត្តិ កិត្តិយស បុណ្យស័ក្តិ ពណ៌សម្បុរ វង្សត្រកូល ភេទ ចំពោះញាតិមិត្ត និងអ្នកដទៃ។

ការប្រកាន់ខ្លួន ឬការវាយឫកពាក្រអឺតក្រទមឆ្មើងឆ្មៃមិនរាប់អានចំពោះញាតិមិត្ត និងចំពោះអ្នកដទៃ ក៏គឺជាប្រការមួយខុសឆ្គងដ៏ធ្ងន់ធ្ងរជាទីបំផុត ដែលយើងត្រូវតែជៀសវាងឱ្យបាន។

ពណ៌សម្បុរ, យសស័ក្តិ,ទ្រព្យសម្បត្តិ,វង្សត្រកូលទាំងអស់នេះមិនមែនជាឧបករណ៏សំរាប់ឱ្យមនុស្សយកមកធ្វើការរើសអើងប្រកាន់អស្មិមានៈ ក្រអឺតក្រទម ឆ្មើងឆ្មៃ ព្រហើនច្រឡើសបើសច្រង៉េងច្រង៉ាងដាក់គ្នានោះឡើយ។ មនុស្សយើងត្រូវតែជម្រុះចោលឱ្យអស់នូវធម៌រើសអើងប្រកាន់ឆ្មើងឆ្មៃ និងភាពព្រហើនកោងកាចគ្មានសុជីវធម៌(discrimination and being immoral)ព្រោះធម៌រើសអើងនេះជាធម៌នាំមកនូវ**អសន្តិសុខ** នាំមកនូវ **សង្គ្រាម** នាំមកនូវ **ការបែកបាក់សាមគ្គី** នាំមកនូវ





**ជម្លោះ** ដែលបញ្ហាអស់ទាំងនេះ គឺសព្វថ្ងៃពិភពលោកកំពុងតែព្យាយាមលុបបំបាត់ដើម្បីសាងសុខសន្តិភាព(Peace)ភាតរភាព និងសកលភាវូបនីយកម្ម (Brotherhood/Globalization) ឱ្យរីកចំរើន នោះគឺបានដល់ការព្យាយាមលុបបំបាត់ការប្រកាន់ពូជសាសន៏មនុស្សជាតិ (Human Racism) នោះឯង។

ពិតមែនហើយ! នៅក្នុងលោកនេះមានមនុស្សមិនតិចនាក់ទេ ដែលស្រឡាញ់ចង់បានឱ្យគេគោរពឱនលំទោនសំពះខ្លួន ព្រោះតែហេតុដូច្នោះហើយ ទើបបានជាគេខិតខំប្រឹងធ្វើឫកពាក្រអឺតក្រទមមិនចងសម្ព័ន្ធមេត្រីជាមួយអ្នកក្រតូចទាប ដើម្បីកុំឱ្យថោក ឬ អ័ព្វរាសីគេ។ គេខំស្លៀកពាក់ស្អាតបាត ប្រើប្រាស់របស់របរទំនើបៗឡូឆាយសព្វបែបសព្វយ៉ាងដើម្បីទាក់ទាញចំណាប់អារម្មណ៏ពីអ្នកដទៃឱ្យវាយតំលៃថាថ្លៃថ្នូរ។ ចំនុចទាំងប៉ុន្មាននេះតើអាចជាការឱ្យធ្វើការវាយតំលៃថាថ្លៃថ្នូរបានទេ? ស្មេរខ្ញុំគិតថាមិនអាចទៅរួចទេ បើពិតជាអាចទៅរួចមែននោះ ម្ល៉េះសមអ្នកមានទ្រព្យទាំងឡាយ គេច្បាស់ជាយកលុយទៅទិញកិត្តិយស-កេរ្តិ៍ឈ្មោះឱ្យល្បីល្បាញមិនខានឡើយ។ ផ្ទុយទៅវិញ បុគ្គលណាដែលកាន់តែ

ក្រអឺតក្រទមវាយឫកខ្ពស់ កាន់តែធ្វើជាអ្នកថ្លៃថ្នូរមិនរាប់រកអ្នកតូចទាបញាតិមិត្ត គឺអ្នកនោះឯងដែលរឹតតែថោកទាប អ័ព្វយសទៅវិញ។ មនុស្សយើងមិនត្រូវឆ្មើងឆ្មៃប្រកាន់ខ្លួនដោយមើលទៅអ្នកដទៃមិនស្មើយើងឡើយ ត្រូវតែគិតថាអ្នកដទៃក៏មានតំលៃដូចយើងដែរ គ្មាននរណាមួយដែលល្អលើសគ្នាវិសេសរហូតធ្វើឱ្យមិនអាចទាក់ទងជាមួយអ្នកដទៃកើតឡើយ។ ខ្មែរយើងមានពាក្យមួយឃ្លាថា "ងើយស្កក ឱនដាក់គ្រាប់" ឬ ពាក្យមួយឃ្លាទៀតថា "ត្រុកៗអ្នកស្រុកមើលងាយ រលាស់គូថខ្វាយ មានឱតមានភ័ន្ត" ដែលនេះជាពាក្យដ៏សំខាន់ក្នុងការដាស់តឿនមនុស្សឱ្យចេះបន្ទាបខ្លួនដើម្បីខ្ពស់ ដើម្បីឱ្យអ្នកដទៃគោរពស្រឡាញ់ពិតមិនមែនគ្រាន់តែគោរពនៅនឹងមុខតែក្រោយខ្នង ខាកស្តោះទឹកមាត់ខ្ពើមឫកនោះទេ។

មិត្តអ្នកអានទាំងឡាយសូមចាំថា មនុស្សមិនត្រូវមើលងាយមនុស្សឡើយ ហើយក៏មិនត្រូវវាយឫកខ្ពស់កប់ពពក តែបែរជាមកជ្រកអាចម៍ជន្លេនដែរ។ ក៏ដូចគ្នាដែរ, យើងក៏រឹតតែមិនត្រូវមើលមនុស្សតែសំបកក្រៅ (Do not judge a man by appearance)នោះទេ ព្រោះថាអ្វីៗវាអាចខុសពីការវាយតំលៃ ឬ ការគិតរបស់យើង ហើយវាក៏មិនអាចកំណត់ថាមនុស្សម្នាក់នៅតែអឺចឹងរហូតគ្មានការវិវត្តន៍ឬក៏ផ្លាស់ប្តូរវាសនាឡើយ។





ដោយពិត! មនុស្សយើងម្នាក់ៗ គឺរស់នៅអាស្រ័យនឹងកម្ម និងផលរបស់កម្ម (Actions and Results) ដែលជាអ្នកដើរតួនាទីដ៏សំខាន់ក្នុងការរៀបចំដំណើរជីវិតឱ្យថ្លៃថ្នូរ ឬ ថោកទាប ឬ អាចនិយាយម្យ៉ាងទៀតថា ជាអ្នកកំណត់ម្ចាស់វាសនាមិនមានព្រះជាម្ចាស់ ឬ ព្រះអាទិទេពជាអ្នករៀបចំឱ្យនោះឯណា! ក្នុងន័យនេះគឺបានដល់ការមានលាភសំណាងវាសនា ឬ ព្រេងសំណាងនោះគឺមិនមែនបានមកពីណានោះទេ តែគឺបានមកពីការខិតខំប្រឹងសន្សំសាងទុកពីពេលមុននោះឯងទេតើ (សំណាងបានពីការសាង)។

មានពេលខ្លះ មនុស្សយើងថ្ងៃសុក្រនៅស្រណុកសុខស្រួលមានទ្រព្យសម្បត្តិស្តុកស្តម្ភ, មានមុខមាត់កិត្តិយស បុណ្យស័ក្តិខ្ពង់ខ្ពស់សោះ តែថ្ងៃសៅរ៍ក៏ជួបទុក្ខលំបាកវេទនា,អស់ទ្រព្យសម្បត្តិ, បាត់បង់កិត្តិយស បុណ្យស័ក្តិដោយប្រការណាមួយ ក៏សឹងមានមិនអាចទស្សន៍ទាយទុកជាមុនបាន។ ដូច្នេះ យើងមិនត្រូវមើលងាយ

អ្នកក្រ, អ្នកតូចទាបជាងខ្លួន ដោយអាងថាខ្លួនមានជាងអស្ចារ្យជាង ឬ ធំជាង,វាយឫកឆ្មើងឆ្មៃប្រកាន់ខ្លួនមិនស្តីរក មិនយកភ្នែកមើលឡើយ ព្រោះថាមនុស្សសុទ្ធតែមានតំលៃ, ចង់ឱ្យគេគោរពសិទ្ធិខ្លួន,ចង់ឱ្យគេអាណិតស្រឡាញ់ខ្លួន និងយកចិត្តទុកដាក់ចំពោះខ្លួនជានិច្ច ទោះបីជាខ្លួនស្ថិតនៅក្នុងកាលៈទេសៈ ឬ ស្ថានភាពបែបណាក៏ដោយ ។

ស្ថិតក្នុងស្ថានភាពដូចម្តេចក៏ដោយ មនុស្សយើងត្រូវចេះធ្វើខ្លួនឱ្យគេគោរពស្រឡាញ់ ទាំងដែលខ្លួនឯងក៏ត្រូវគោរពគេវិញឱ្យបានស្មើជានិច្ច ។ សូមកុំច្រឡំឱ្យសោះវាសនាគឺមនុស្សជាអ្នករៀបចំចាត់ចែង និងធ្វើជាម្ចាស់វាតែមិនមែនវាជាអ្នករៀបចំចាត់ចែងមនុស្សឡើយ ហើយមនុស្សយើងក៏មិនមែននៅតែឱនអន់, ក្រីក្រ ឬ តូចរហូតដែរ ឱ្យតែមានការតស៊ូប្រឹងប្រែងអត់ធ្មត់ និងព្យាយាម ក៏នឹងអាចធ្វើការផ្លាស់ប្តូរមុខមាត់របស់ខ្លួនជាក់ជាមិនខាន (មានមិនដែលមួយត ឯក្រវិញក៏មិនដែលមួយជាតិដែរ) ។ បើប្រៀបធៀបទៅវាសនារបស់មនុស្សយើង ក៏មិនខុសអីពីមេឃដែរ គឺជួនក៏មានភ្លៀង ជួនក៏អត់ភ្លៀង ជួនអ័ព្ទអួរ ជួនក៏ស្រឡះ





ទៅវិញ ឯមនុស្សក៏អីចឹងដែរ ពេលខ្លះមហាសេដ្ឋីក៏អាចក្លាយជាអ្នកសុំទានគេ ហើយអ្នកសុំទានគេក៏អាចក្លាយជាអ្នកមានទ្រព្យស្តុកស្តម្ភបាន ដូច្នេះអ្វីដែលសំខាន់គឺកុំមើលងាយ ឬ សើចចំអកមនុស្សអីពាក្យខ្មែរយើងថា"អូនអើយកុំសើចបង ប្រយ័ត្នពៀរឆ្លងម្តងម្នាក់ណា" ។ ខ្ញុំមានសំដីចង់និយាយមួយឃ្លាថា"មនុស្សយើងនៅពេលចង់ធ្វើឫកឱ្យខ្ពស់ពេក គឺរឹតតែទាបទៅវិញទេ"ហើយត្រូវជឿចុះថា"កាន់តែខ្ពស់ ក៏កាន់តែមើលឃើញច្បាស់ងាយស្រួលនឹងប៉ះខ្យល់ព្យុះបោកបក់ និងងាយរងគ្រោះថ្នាក់ដោយប្រការផ្សេងៗណាស់" ដែលនេះគឺវាដូចគ្នាទៅនឹងចំនុចដែលយើងកាន់តែឡើងខ្ពស់យ៉ាងណា ពេលធ្លាក់យើងក៏កាន់តែរងគ្រោះថ្នាក់ខ្លាំងដូច្នោះដែរ ។

ធ្វើជាមនុស្សគួរកុំសំដែងឫកខ្ពើមព្រះធរណីពេក ព្រោះអីនៅលើលោកនេះគ្មាននរណាម្នាក់ ដែលអាចមិនដើរលើព្រះធរណីឡើយ ហើយថែមទាំងត្រូវអាស្រ័យនូវកិច្ចការផ្សេងៗជាច្រើនទៀតជាមួយនឹងព្រះធរណី ។ ក៏ដូចគ្នាដែរ, ត្រូវចេះធ្វើសេចក្តីប្រៀបធៀបដូច្នេះថា"សូម្បីតែខ្លែង ដែលគេធ្វើបង្ហោះឡើងទៅ

លើអាកាស គឺវាអាចហោះទៅបាន លុះត្រាតែវាត្រូវបានគេធ្វើយ៉ាងត្រឹមត្រូវតាមសំនុំលក្ខណៈ, មានខ្សែ និងមានខ្យល់ផងដែរ ហើយវាអាចនឹងធ្លាក់មកលើដីបានគ្រប់ពេលវេលា ដោយសារមិនមានខ្យល់បក់, ដោយសារដាច់ខ្សែ, ដោយសារខ្យល់ខ្លាំងពេក ឬ ដោយសារមនុស្សជាអ្នកទាញវាទំលាក់ចុះមក”។ ត្រង់ចំនុចនេះមានសេចក្តីស៊ីជំរៅយ៉ាងណានោះ ខ្ញុំមិនចាំបាច់ពន្យល់ឱ្យក្បោះក្បាយពេកទេ ទុកឱកាសឱ្យប្រិយមិត្តអ្នកអានធ្វើការត្រិះរិះពិចារណាដោយខ្លួនឯងចុះ ព្រោះថាវាមានសារសំខាន់ណាស់( សូមចាំឱ្យច្បាស់ ជីវិតមិនមែនសំរាប់ការមើលងាយនោះទេ) ។

ចំពោះបញ្ហានេះ ស្មេរខ្ញុំគិតថាមិត្តអ្នកអានភាគច្រើនច្បាស់ជាធ្លាប់បានដឹង និងឃើញខ្លះហើយនៅក្នុងជីវិតពិតប្រចាំថ្ងៃដែលមានអ្នកខ្លះធ្លាប់មានជីវប្រវត្តិពីអតីតៈដ៏ជូរចត់កំសត់ទុគិត លំបាកវេទនាយ៉ាងក្រៃលែង តែក្រោយមកក៏បែរជាមានភ័ព្វវាសនាដ៏គួរឱ្យស្ញប់ស្ញែងជាទីបំផុត។ ខ្ញុំសូមលើកយករឿងរ៉ាវពិតមួយរបស់ស្ត្រីម្នាក់នៅក្នុងសង្គមខ្មែរយើងបច្ចុប្បន្ននេះ ដែលកាលពីដើមឡើយ គាត់គឺជាស្ត្រីដែលធ្លាប់មានការលំបាកស្វិតស្វាញល្វីងជូរចត់





កំសត់វេទនាស្ទើរតែនិយាយចេញមកមិនរួច ខណៈពេលដែលគាត់ត្រូវបានសម្ភាសពីជីវប្រវត្តិពិតកាលពីអតីតៈរបស់ខ្លួន។ ស្ត្រីម្នាក់នេះមានឈ្មោះថា **លឹម-ឈីវហួរ** សព្វថ្ងៃគាត់បានកែប្រែនូវវាសនាដ៏អភ័ព្វនោះ មកជាមនុស្សដែលមានកិត្តិយសឧត្តមខ្ពង់ខ្ពស់ និងមានទ្រព្យសម្បត្តិដ៏ច្រើនមហាសាល ដែលត្រូវបានគេហៅថា “**ឧកញ៉ាដែលមានការតស៊ូដ៏ស្វិតស្វាញ**”(The Tender Tycoon) ហើយនៅពេលដែលគាត់ឆ្លើយតបទៅនឹងសំនួរដែលត្រូវបានសួរថា តើអ្នកស្រីមានជីវិតពីអតីតៈយ៉ាងដូចម្តេចនោះ? អ្នកស្រីបានឆ្លើយថា “**ជីវិតខ្ញុំគឺដូចគ្នានៅនឹងនាងបដាចារនៅក្នុងរឿងអ៊ីចឹង**”។ មិត្តអ្នកអានច្បាស់ជាឆ្ងល់ថា តើរឿងនោះវាយ៉ាងមេចហើយ? ខាងក្រោមនេះគឺជារឿងរ៉ាវទាំងស្រុងដែលខ្ញុំបានដកស្រង់ចេញពីទស្សនាវដ្តីវាមានសេចក្តីដូចតទៅៈ

ទោះបីជាសំពាធគ្រួសារ និងព្រហ្មលិខិតបានដាក់បន្ទុកធ្ងន់យ៉ាងណាក៏ដោយក៏ស្ត្រីរូបនេះមិនទន់ជ្រាយនិងអស់សង្ឃឹមនៅក្នុងជីវិតនោះទេ គឺនាងបានខិតខំពុះពារនូវរាល់ឧបស័គ្គទាំងឡាយដើម្បីកូនជាទីស្រឡាញ់ទាំងទ្វេរបស់នាង ទោះបីជាដឹងថានេះគឺជា

ភារៈដ៏ធ្ងន់ធ្ងរសំរាប់មនុស្សស្រីក៏ដោយ ។ ស្ថិតនៅក្នុងការិយាល័យដ៏ធំល្វឹងល្វើយដែលបានដាក់លំអនូវគ្រឿងឥស្សរិយយសដែលបានផ្តល់ដោយសារស្នាដៃជួយរួមចំណែកក្នុងការកសាងជាតិ និងរូបថតអនុស្សាវរីយ៍ជាច្រើន នៅពីក្រោយខ្នងស្ត្រីម្នាក់ដែលធ្លាប់តែហត់នឿយ និងត្រូវប៉ះនូវកំដៅថ្ងៃ និងការផ្សងជីវិតនៅលើទូកកណ្តាលកោះជារៀងរាល់ថ្ងៃស្ទើរតែរកពេលសំរាកមិនបាន ទម្រាំតែបានមកអង្គុយស្រួលនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់យ៉ាងដូច្នេះ ។ លោកស្រីបានមានប្រសាសន៍ថា: ទំរាំមានថ្ងៃនេះ ខ្ញុំបានចំនាយពេលវេលាជិតពាក់កណ្តាលជីវិតរស់នៅផ្សងព្រេងលើកោះ និងជាកម្មការិនីលីឥវ៉ាន់ពីកាណូតពេលរាត្រី ដែលជាពេលគេគេងគឺខ្ញុំមិនបានគិតថាជាការងារធ្ងន់ស្រាលនោះទេធ្វើយ៉ាងណាឱ្យតែបានអង្ករច្រកឆ្នាំងមួយពេលៗនោះជាការប្រសើរបំផុត ។

អតីតកាលពិតជាបានកន្លងផុតទៅយ៉ាងឆាប់រហ័សណាស់ ហើយក៏បានជំនួសមកវិញនូវបច្ចុប្បន្នកាល ដែលនឹកស្មានមិនដល់ ដោយបានប្រែក្លាយមុខមាត់ពីស្ត្រីដ៏ទន់ខ្សោយមកជាស្ត្រីអ្នកជំនួញដ៏ល្បីឈ្មោះនោះលោកស្រី **លឹម-ឈីវហួរ** បានមានប្រសាសន៍





ទាំងទឹកមុខស្រពោន ដែលមានទាំងទឹកភ្នែករលីងរលោង និងសំឡេងអួលដើមកថា: ខ្ញុំឈានដល់ថ្ងៃនេះគឺខ្ញុំបានជួបនូវរឿងរ៉ាវដ៏ជូរចត់ក្នុងឆាកជីវិតច្រើនណាស់ ដោយខ្ញុំត្រូវធ្វើជាកម្មការិនីលីសែងឥវ៉ាន់ពីកាណូតនាពេលយប់ ហើយខ្ញុំត្រូវធ្វើការរហូតទល់ភ្លឺ ហើយពេលភ្លឺខ្ញុំត្រូវឡើងទៅផ្សារដើម្បីទិញនំចំណី ឬ ផ្លែឈើទុកសំរាប់លក់ឱ្យពួកកម្មករនៅផែពេលដែលកាណូតមកដល់ ។

លោកស្រីបន្តទៀតថា: មុនពេលខ្ញុំមកធ្វើជាកម្មការិនីលីសែងនេះ គឺបន្ទាប់ពីរបបប៉ុល-ពត ខ្ញុំបានទៅរស់នៅជាមួយឪពុកម្តាយក្មេកបានរយៈពេល ១ឆ្នាំ ប៉ុន្តែដោយសារមានការលំបាកពេកទាំងផ្លូវកាយ និងចិត្ត ខ្ញុំក៏បានមករស់នៅជាមួយនឹងម្តាយរបស់ខ្ញុំជាស្ត្រីមេម៉ាយមានកូនស្រី៥នាក់ក្នុងបន្ទុក ។ ខ្ញុំនិងគ្រួសារព្រមទាំងបងប្អូនស្រីទាំងអស់បានប្រកបរបរធ្វើស្រែចំការ និងដាំដំណាំ ព្រោះអីជំនាន់នោះមិនដឹងរកស៊ីអ្វីទេ ទើបតែបែកពីរបបប៉ុល-ពត ។ដោយសារតែការធ្វើស្រែចំការពុំសូវបានផល និងប្រជាពលរដ្ឋមករស់នៅច្រើន ខ្ញុំនិងគ្រួសារបានប្រកបរបរជាអ្នករាវងារដើម្បីយកទៅដូរអង្ករយកមកផ្គត់ផ្គង់ជីវភាពគ្រួសារ ហើយបើ

ពេលណារកបានច្រើននោះ ខ្ញុំក៏ដូរជាសំលៀកបំពាក់ផងដែរ ។ រកស៊ីរបរនេះបាន ១ឆ្នាំ ខ្ញុំក៏បានយកងាវមកលក់នៅវាលរេញ ខ័ណ្ឌព្រៃនប់ខេត្តកំពត( សព្វថ្ងៃក្រុងព្រះសីហនុ) តែនៅតែដូរអង្ករដដែល ។

ដោយសារតែស្ត្រីរូបនេះជាមនុស្សឧស្សាហ៍ នោះនាងមិនបានបណ្តោយឱ្យពេលវេលាកន្លងទៅ ដោយឥតប្រយោជន៍ឡើយ ដោយនាងឆ្លៀតពេលទំនេរសំរាកថ្ងៃត្រង់ចូលព្រៃជាមួយប្តីដើម្បីកាប់ឈើធ្វើអុសដូរអង្ករ គឺធ្វើយ៉ាងណាផ្គត់ផ្គង់ជីវភាពគ្រួសារកុំឱ្យខ្វះខាត ។

លោកស្រីបន្តថា: គ្រួសារខ្ញុំសល់អង្ករច្រើនពីការដូរងាវ និងអុស ដូច្នេះម្តាយរបស់ខ្ញុំបានច្នៃដោយយកមែកឈើដែលអាចធ្វើជាមេស្រាបានមកបិទស្រាស ដូរអង្ករជាមួយនឹងកម្មកររវៀតណាម ឯខ្ញុំដើររែកស្រាលក់តាមភូមិ ហើយបាយស្រាដែលនៅសល់ចិញ្ចឹមជ្រូកបានទៀត ។ ការប្រកបរបរនេះបាន១ឆ្នាំ ពុំសូវរីកចំរើនទៅមុខ យើងក៏សំរេចចិត្តទុកកូនឱ្យម្តាយមើល ហើយពីរនាក់ប្តី ប្រពន្ធទៅធ្វើជាកម្មករលីសែងពីកប៉ាល់លើកោះបន្តទៀត ។





ការធ្វើជាកម្មករនេះ គឺយើងត្រូវធ្វើពេលយប់រហូតទល់ភ្លឺ បើមិនអីចឹងទេយើងពុំអាចទៅបើកលុយពីថៅបានឡើយ ។ ទោះបីខ្ញុំមិនអាចដេកគ្រប់គ្រាន់ក៏ដោយ ពេលថ្ងៃខ្ញុំត្រូវឡើងផ្សារទិញអីវ៉ាន់នំចំណីលក់ឱ្យកម្មករលើកប៉ាល់ហូប ។

ដោយសារការព្យាយាម និងចេះសន្សំសំចៃបន្ទាប់ពីធ្វើការជាកម្មករ និងលក់ឥវ៉ាន់គាត់ក៏បានបើកជាហាងដ៏តូចមួយ ។ លោកស្រីបានគូសបញ្ជាក់ថា: បន្ទាប់ពីការសន្សំលុយដែលរកបានមកដោយលំបាកនោះ ខ្ញុំបានបើកជាហាងលក់គុយទាវ និងលក់បាយមួយសំរាប់ឱ្យកម្មករ និងពួកទូកនៅទីនោះហូប ហើយខ្ញុំបានប្រកបរបរនេះអស់រយៈពេលជាង៣ឆ្នាំ ។ តំបន់នោះក៏ត្រូវបានរដ្ឋាភិបាលប្តូរឱ្យមកនៅស្ទឹងហាវ នៅពេលមកដល់ទីនោះខ្ញុំលក់គុយទាវ និងបាយដដែលហើយរបរនេះធ្វើបាន១ឆ្នាំជាងប្តីខ្ញុំក៏បានសំរេចចិត្តទៅរកស៊ីនៅថៃ តែដោយសារសម័យនោះយើងមិនទាន់មានលិខិតឆ្លងដែន ដូច្នេះប្តីខ្ញុំត្រូវបានគេចាប់ដាក់គុកនៅប្រទេសថៃស្របពេលជាមួយគ្នានោះដែរ កូនស្រីរបស់ខ្ញុំក៏លង់ទឹកស្លាប់ទៀតផង ។

ដោយសារតែសំពាធនៃក្តីទុក្ខដ៏ធ្ងន់ និងការប្រកបមុខរបររកស៊ីពុំសូវបានផលផង លោកស្រីក៏បានប្តូរមករកស៊ីនៅផ្ទះវិញ ដោយទៅសាងទំនិញពីទូកមកលក់នៅក្នុងផ្ទះ ទីនោះហើយដែលលោកស្រីមានការរីកចំរើនរហូតមកដល់សព្វថ្ងៃនេះ។ លោកស្រីបន្តថាៈ ដោយសារការប្រកបរបរនេះយូរទៅមានការជឿជាក់គ្នាទៅវិញទៅមកនោះ គេក៏បានដាក់ទំនិញឱ្យខ្ញុំលក់ដូរកាន់តែច្រើន ដូចជា ទូរទស្សន៍ ម៉ាញ៉េ ទឹកក្រូច ប៊ីយែ និងគ្រឿងទេសគ្រប់មុខ ដូច្នេះប្រជាជននៅទីក្រុងភ្នំពេញ នៅពេលដែលគេមកទិញទំនិញនៅទីនេះ គឺគេទិញពីខ្ញុំទាំងអស់ទៅលក់នៅភ្នំពេញ (ដឹកតាមរថភ្លើងសម័យនោះ)។

លោកស្រីបន្ថែមទៀតថាៈ ការរកស៊ីនេះកាក់កបគ្រាន់បើ តែនៅមានបញ្ហាជាច្រើនដោយសារខ្លួនជាស្រី ហើយត្រូវសាងទំនិញនៅកណ្តាលសមុទ្រ និងជួបប្រទះនូវការប្លន់ជាញឹកញាប់ ព្រោះសម័យនោះមិនទាន់មានការបង់ពន្ធជូនរដ្ឋទេ។ ក្រោយមករដ្ឋាភិបាលតំរូវឱ្យបង់ពន្ធនៅក្រុងព្រះសីហនុ តែវាច្រើនដំណាក់ពេក យើងក៏បើកក្រុមហ៊ុននៅភ្នំពេញ ដើម្បីភាពងាយស្រួលដល់





អតិថិជន ហើយពេលនោះយើងលក់តែគ្រឿងអេឡិចត្រូនិចទេតែដោយមិនសូវកាក់កប ក៏បានប្តូរមកនាំស្រាចូលវិញ ព្រោះវាបានផលល្អគ្រាន់បើ។

ជីវិតជាស្ត្រីដ៏កំសត់បានកែប្រែក្លាយមកជាអ្នកជំនួញដ៏ខ្លាំងពូកែ និងមានក្រុមហ៊ុនខ្លួនឯងក្នុង ឆ្នាំ១៩៩៣។ លោកស្រីបានបញ្ជាក់ថាៈ ទម្រាំតែមានថ្ងៃនេះគឺវាមានការលំបាកណាស់ដោយខ្ញុំត្រូវដើរចុះស្រាវជ្រាវនូវប្រភេទស្រាផ្សេងៗ ដែលអតិថិជនចូលចិត្តនៅតាមហាងឪស្ថ និងហាងខារ៉ាអូខេនាពេលយប់ ហើយខ្ញុំត្រូវហូបស្រាជាមួយនឹងភ្ញៀវ អ្នកដែលមើលតែសំបកក្រៅ គេមិនបានឱ្យតំលៃយើងទេ តែខ្ញុំត្រូវតែធ្វើ។ ដោយសារការតស៊ូរបស់ខ្ញុំទើបខ្ញុំអាចបើកសាខាក្រុមហ៊ុនបានគ្រប់ខេត្តក្រុង ដើម្បីផ្តល់ការងារ និងចំនូលដល់ប្រជាពលរដ្ឋខ្មែរជាច្រើន។ នៅឆ្នាំ២០០០ លោកស្រីបានបង្កើតក្រុមហ៊ុនផលិតទឹកសុទ្ធ, សង់សណ្ឋាគារ, សង់ផ្ទះល្វែងលក់,ធ្វើកំពង់ផែនៅស្ទឹងហាវ និងតំបន់សេដ្ឋកិច្ចពិសេសនៅភ្នំពេញទាំងអស់នេះសុទ្ធតែជាកំលាំងញើសឈាមរបស់ខ្លួន។

ជាការពិតណាស់ បើរំលឹកពីការសិក្សាវិញគឺលោកស្រីមិន

បានសិក្សាជ្រៅជ្រះទេ ដោយសារលក្ខខ័ណ្ឌសង្គម(សម័យប៉ុល-ពតផ្លាស់ប្តូរទីលំនៅញឹកញាប់ពេក) និងដោយសារជីវភាពគ្រួសារក្រីក្រពេក គឺក្នុងត្រកូលមួយដែលមានបងប្អូនសុទ្ធតែស្រី ៧នាក់ (ឪពុកលក់ការ៉េម)នៅក្នុងភូមិទួល,ស្រុកព្រៃនប់,ខេត្តកំពត(សព្វថ្ងៃក្រុងព្រះសីហនុ)។ នៅសម័យប៉ុលពតលោកស្រីក៏ដូចជាប្រជាជនខ្មែរដទៃទៀតដែរ គឺសុទ្ធតែត្រូវបែកបាក់ញាតិមិត្តគ្រួសារ និងត្រូវបង្ខំឱ្យធ្វើការយ៉ាងវេទនា ហើយបាយទឹកហូបមិនគ្រប់គ្រាន់ទៀតផង។ លោកស្រីបានឱ្យដឹងថា:បន្ទាប់ពីប្តីរបស់ខ្ញុំបានជាប់គុកនៅប្រទេសថៃអស់រយៈពេលជាច្រើនឆ្នាំមកនៅឆ្នាំ១៩៨៧ យើងក៏បានជួបជុំគ្នាវិញ និងរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃ ហើយឥឡូវគាត់គឺជាថៅកែរោងចក្រផលិតក្រដាសមួយនៅកម្ពុជា។

លោកស្រីបានប្រដូចជីវិតខ្លួនទៅនឹង**នាងបដាចារ** ហើយវាក៏ស្រដៀងគ្នានឹងខ្សែភាពយន្តមួយ ដែលបានដាក់បញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍CTN ដែលមានចំណងជើងថា"កូនប្រសារស្រី" ដោយលោកជំទាវបានគូសបញ្ជាក់ថា: នេះជាខ្សែជីវិតពិតរបស់ខ្ញុំគ្រាន់តែត្រូវបានកែច្នៃខ្លះៗ ទៅតាមអ្នកដឹកនាំរឿងតែប៉ុណ្ណោះ។





តាមរយៈសាច់រឿងនេះ ខ្ញុំចង់ឱ្យក្មេងស្រករក្រោយ និងអ្នកម្តាយក្មេកទាំងឡាយឱ្យមានការតស៊ូ និងទទួលស្គាល់កូនប្រសារស្រីដូចជាកូនបង្កើតរបស់ខ្លួន។ ទាំងអស់គ្នាត្រូវតែស្អប់ខ្ពើមការជិះជាន់ការរើសអើង និងការប្រមាថមើលងាយ ហើយមានជីវិតត្រូវតែមានការតស៊ូរើបំរាស់ អត់ធ្មត់ ម៉ឺងម៉ាត់ព្យាយាម និងត្រូវតែរឹងប៉ឹងក្លាហាន និងមានក្តីសង្ឃឹមជានិច្ច ទើបធ្វើឱ្យជីវិតមានភាពជោគជ័យ និងស្រស់ថ្លា។ មិនថាខ្លួនជាស្រីទេត្រូវតែគិតថាអ្វីដែលមនុស្សប្រុសអាចធ្វើបាន មនុស្សស្រីក៏អាចធ្វើបានដូចគ្នាឱ្យតែមានការតស៊ូអត់ធ្មត់ និងព្យាយាម ហើយក៏មិនត្រូវប្រកាន់គំនិតថា "**កូនស្រីវិលចង្ក្រានមិនជុំនោះទេ**" ព្រោះវាជាគំនិតចាស់គំរិលពេកហើយៗមិនមានការអភិវឌ្ឍទៀតផង។

ស្ថិតក្នុងវ័យ៤៩ឆ្នាំមានកូននៅក្នុងបន្ទុកគ្រួសារ៣នាក់ និងជាស្ត្រីដ៏ឆ្នើមផ្នែកជំនួញ និងជានាយិកាក្រុមហ៊ុនជាច្រើន ដូចជា: Attwood Import Export Co.LTD. តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ, Japan Cambodia Development Co. LTD, APL Cambodia Co. LTD.ដែលមានក្រុមហ៊ុន

ដ៏ធំមួយឈ្មោះថា Attwood Investment Group និងជាអនុប្រធានសភាពាណិជ្ជកម្មកម្ពុជាផងដែរ ហើយដោយសារមានស្នាដៃក្នុងការចូលរួមកសាងជាតិដ៏ច្រើននោះ លោកស្រីជំទាវក៏បានទទួលងារជា **ឧកញ៉ា ២**

នេះគឺជារឿងរ៉ាវពិតមួយនៃមនុស្សម្នាក់ក្នុងចំនោមមនុស្សជាច្រើននាក់ទៀត ដែលមានការតស៊ូក្នុងឆាកជីវិតដ៏ស្វិតស្វាញដើម្បីអភិវឌ្ឍន៍កែប្រែមុខមាត់ខ្សែជីវិត និងវាសនាដ៏អភ័ព្វពីអតីតកាល ឱ្យមកជាបុគ្គលម្នាក់ថ្មីស្រឡាងប្រកបដោយទ្រព្យសម្បត្តិហូរហៀរ និងកិត្តិយសខ្ពង់ខ្ពស់នៅក្នុងសង្គម។ មនុស្សប្រភេទនេះគេអាចប្រើពាក្យប្រដូចមួយថា "មនុស្សឈាមពេជ្រ **ឆ្អឹងមាស** ឬ **មនុស្សវាសនាទេវតានោះឯង**"។ នៅមានមនុស្សជាតួយ៉ាងដ៏សំខាន់ជាច្រើនទៀត ដែលស្រដៀងគ្នានឹងរឿងនេះ ក្នុងនោះមានដូចជា **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន-សែន និងសម្តេចព្រះសង្ឃរាជ ជួន-ណាត** ជាដើម។ ខ្ញុំសូមអធ្យាស្រ័យដោយនៅក្នុងធម៌ទី៤នេះលើកយករឿងរ៉ាវរបស់លោកស្រីជំទាវឧកញ៉ា **លឹម~ឈីវហួរ** វែងពេក នេះក៏ព្រោះខ្ញុំគិតថាវាមានសារសំខាន់ខ្លាំងណាស់សំរាប់





មិត្តអ្នកអានក្នុងការត្រិះរិះពិចារណាដោយហេតុថាមនុស្សមិនត្រូវមើលងាយមនុស្ស ហើយមនុស្សត្រូវតែតស៊ូព្យាយាមក្នុងឆាកជីវិត ព្រោះមនុស្សជាអ្នករៀបចំវាសនាអនាគតខ្លួនឯង (សេចក្តីលំបាកគឺជាទ្រព្យដ៏ប្រសើររបស់មនុស្សគ្រប់រូប)។

ព្រះសមណគោតម ព្រះអង្គគឺជាគំរូដ៏ល្អបំផុតសំរាប់យើងរាល់គ្នាក្នុងការប្រព្រឹត្តនូវចំណុចធម៌ទី៤គឺ **សមានត្តតា** (ការបន្ទាបខ្លួនស្មើ ,ការមិនប្រកាន់ខ្លួនរើសអើងឆ្មើងឆ្មៃ...)នេះ ព្រោះរាល់ទង្វើទាំងអស់ដែលទ្រង់បានធ្វើ គឺសុទ្ធតែប្រកបដោយទឹកចិត្តអាណិតស្រឡាញ់ពិតដែលស្តែងចេញពី **ព្រហ្មវិហារធម៌** ដ៏ស្មោះស្មើចំពោះសព្វសត្វទូទៅមិនរើសមុខ។ រាល់ការយាងទៅសំដែងព្រះធម៌, ការជួបប្រាស្រ័យជាមួយបរិស័ទ,ការទទួលកិច្ចនិមន្ត និងការយាងទៅប្រោសសត្វ គឺព្រះអង្គទ្រង់មិនដែលមានព្រះឱស្ឋថា "ទេ" ព្រោះបុគ្គលនេះយ៉ាងនេះបុគ្គលនោះយ៉ាងនោះម្តងណាឡើយ ឱ្យតែមនុស្សសត្វណាមួយពេញចិត្តនឹងព្រះអង្គ ឬ មានឧបនិស្ស័យនឹងព្រះធម៌។ ព្រះអង្គមិនដែលមានអស្មិមានះ ប្រកាន់រើសអើងដោយអាងថាព្រះអង្គជាក្សត្រ ឬ មានឋានៈជាព្រះពុទ្ធទេ ជានិច្ច

កាល ព្រះអង្គតែងតែនៅជាមួយសព្វសត្វដោយក្ដីស្រឡាញ់ ក្នុងឋានៈជាបង, ជាគ្រូ, និងជាឪពុកម្ដាយ...មិនថាបុគ្គលណាមកពីត្រកូលណា, ប្រទេសណា, ជាតិសាសន៍ណា, អ្នកក្រុង, អ្នកស្រែ, អាក្រក់-ល្អ, ស-ខ្មៅ និងមានជម្ងឺរោគាប្រភេទណានោះឡើយ។

មិត្តអ្នកអានឃើញទេ? បើនិយាយពីឋានៈមុខមាត់របស់ព្រះអង្គ គឺព្រះអង្គខ្ពង់ខ្ពស់ដាច់ពីមនុស្សសាមញ្ញធម្មតា តែបើនិយាយពីឥរិយាបថវិញ គឺព្រះអង្គរួសរាយរាក់ទាក់ល្អូកល្អឺនជាទីបំផុតជាមួយមនុស្សសត្វទាំងឡាយ។ ចុះយើងវិញ? សាមញ្ញប្រហែលៗគ្នាមួយដំបរ និងបួនសោះ អីក៏ចាំបាច់វាយឫកអ្វីម្ល៉េះ? ខ្លាចគេមិនដឹងថាគ្រាន់បើឬ? កុំគ្រាន់បើពេក! ព្រោះនៅដើរលើដីដូចតែគ្នាហ្នឹង! ម្យ៉ាងវិញទៀត បើរឹតតែប្រឹងជន្មើតឫកគឺវាកាន់តែទាបទេតើ! ផ្ទុយទៅវិញ បើធ្វើឫកពាស្រស់ស្រាយរួសរាយរាក់ទាក់, មិនខ្លាចឆ្លងក្រ, មិនខ្លាចអព្វរាសី និងមិនប្រកាន់រើសអើងឆ្មើងឆ្មៃស្មោះស្មើដូចគេដូចឯងទៅនោះ ក៏វារឹតតែខ្ពង់ខ្ពស់ថ្លៃថ្នូរថែមទៀតដែរ។

ពិតមែនហើយ! ចំនុចទាំងប៉ុន្មានខាងលើដែលខ្ញុំបានខិតខំ





ប្រឹងនិយាយមកនេះគឺដើម្បីកុំឱ្យមនុស្សយើងស្អប់ខ្ពើមគ្នា,ប្រកាន់រើសអើងជាតិ-វង្សត្រកូល-ពណ៌សម្បុរ-យសស័ក្តិ-ទ្រព្យសម្បត្តិចំពោះគ្នានិងជាពិសេសគឺមិនត្រូវបន្តុះបង្អាប់បំបាក់ស្មារតីគ្នាឡើយ ត្រូវតែស្រឡាញ់គ្នាឱ្យដូចបង ប្អូន និងផ្ដល់កំលាំងចិត្តដល់គ្នា។ យ៉ាងណាក៏ដោយ ខ្ញុំអ្នកសរសេរយល់ថាបញ្ហារើសអើងប្រកាន់ខ្លួននៅតែមានជាធម្មតា តែខ្ញុំសូមឱ្យមនុស្សយើងមានការតស៊ូព្យាយាម និងក្លាហានជំនះឱ្យបាន ដើម្បីកែប្រែបញ្ហាវាសនាដ៏អាក្រក់ទាំងនោះឱ្យមកជារឿងល្អជោគជ័យសំរាប់ជីវិតវិញ( មានការជិះជាន់នាំឱ្យមានការរើបំរាស់ ហើយមានការរើបំរាស់ទើបមានការផ្លាស់ប្ដូរ) ។ ជាធម្មតាទេ, ការរើសអើងមើលងាយ, ការពោលពាក្យទ្រគោះបោះបោកដៀលត្មិះ និងការជិះជាន់ គឺតែងតែកើតមានក្នុងលោកនេះ សូម្បីតែព្រះពុទ្ធផ្ទាល់ ក៏ព្រះអង្គធ្លាប់ទទួលរងដែរ។

មានពេលមួយ,ព្រះអង្គរួមជាមួយនឹងសាវ័កជាច្រើនទៀត និងព្រះអានន្ទផងដែរ ទ្រង់បានយាងនិមន្តបិណ្ឌបាត្រតាមភូមិជាប្រក្រតី ស្រាប់តែពេលនោះមានអ្នកភូមិខ្លះដែលមិនពេញចិត្តបាន

ជេរប្រទេចផ្តាសាដោយប្រការផ្សេងៗចំពោះព្រះអង្គ និងសាវ័ក។ ព្រះអានន្ទនៅពេលបានឮនូវពាក្យជេរផ្តាសាដ៏អាក្រក់ ទាំងនោះ ហើយក៏បានទូលព្រះពុទ្ធថាសូមព្រះអង្គកុំគង់នៅ និងបិណ្ឌបាត្រក្នុងភូមិនេះតទៅទៀតអី ហើយសូមទៅកន្លែងផ្សេងទៀត តែព្រះអង្គមិនព្រមទៅទេ ហើយប្រាប់អានន្ទថាបើទៅនៅកន្លែងផ្សេងទៀតក៏នៅតែមានការមិនពេញចិត្ត និងពាក្យមិនពីរោះស្តាប់ដូច្នេះដែរ។ ព្រះអានន្ទបន្តទៀថា បើដូច្នោះទៅកន្លែងផ្សេងទៀតព្រះអង្គថា ចុះបើកន្លែងថ្មីនោះនៅអ៊ីចឹងទៀត? ព្រះអង្គថានៅលើលោកនេះគ្មានទីបំផុតទេ អានន្ទអើយចំពោះការមិនពេញចិត្ត និងពាក្យពេចន៏អាក្រក់ស្តាប់នោះ ព្រោះថាបើទោះយើងធ្វើល្អ-ត្រូវក៏មានអ្នកអាក្រក់គេរិះគន់,បើយើងធ្វើខុស-អាក្រក់ ក៏មានអ្នកល្អគេរិះគន់ដែរ។ ដូច្នេះមានតែខ្លួនឯងទេដែលត្រូវតែធ្វើល្អ,ខិតខំសាងប្រយោជន៏-សាងអនាគតសំរាប់ខ្លួនឯង ហើយក៏មិនត្រូវចាលចាញ់ដោយសារតែពាក្យរបស់អ្នកដទៃនោះដែរ( មានខ្លួនជាទីស្រឡាញ់) ។

មួយវិញទៀត,អ្វីដែលខ្ញុំចង់និយាយនៅក្នុង **សមានត្តតា**





( ការបន្ទាបខ្លួនស្មើឬការធ្វើខ្លួនដោយដឹងពីតួនាទី-ឋានៈសមរម្យ) នេះក៏ទាក់ទងទៅនឹងបញ្ហាឥរិយាបថរបស់បុគ្គលគ្រប់រូបដែលត្រូវប្រព្រឹត្តចំពោះគ្នាគ្រប់ពេលវេលា ទាំងនៅក្នុងគ្រួសារ, អង្គភាពការងារ និងទីសាធារណៈ ឬក្នុងសង្គមផងដែរ។ ការដឹងខ្ពស់ទាប-ឋានៈតួនាទី គឺជារឿងដ៏សំខាន់ណាស់នៅក្នុងជីវិតប្រចាំថ្ងៃ ព្រោះថាបើយើងមិនចេះសំដែងនូវសេចក្តីគោរពកោតខ្លាចត្រកូលរៀមច្បង, ចាស់ទុំ, អ្នកមុខអ្នកការ-តូច-ធំ ,ព្រះសង្ឃ,ដូនជី-តាជីជាដើមទេនោះ ក៏ឈ្មោះថាជាមនុស្សគ្មានសីលធម៌-សុជីវធម៌ និងជាមនុស្សឈ្លើយ គ្មានពូជពង្ស គ្មានមេបាប្រដៅ ហើយអ្នកដទៃគេនឹងស្អប់ខ្ពើមមិនសេពគប់រាប់រក។ ក្នុងន័យនេះខ្ញុំចង់និយាយថានៅក្នុងគ្រួសារកូនត្រូវតែចេះគោរពឪពុកម្តាយ-យាយ-តា-អ៊ំ-ពូមីង និងមនុស្សដែលមានវ័យចាស់ជាង, នៅក្នុងសាលារៀនសិស្សនិស្សិតត្រូវតែគោរពលោកគ្រូ-អ្នកគ្រូ-មិត្តភ័ក្តិផងគ្នា, នៅកន្លែងការងារត្រូវចេះគោរពចៅហ្វាយនាយ (មេកើយ)និងមិត្តភ័ក្តិផងគ្នា និងនៅក្នុងសង្គមត្រូវចេះគោរពអ្នកធំមានបុណ្យស័ក្តិ,អ្នកគ្រប់គ្រង ឬ មនុស្សចាស់ទុំទូទៅ,ព្រះសង្ឃនិងដូនជី-តាជី។ ធ្វើដូច្នេះ

ទើបឈ្មោះថាជាមនុស្សថ្លៃថ្នូរ មានសីលធម៌ និងគួរដល់ការគោរព ឱ្យតំលៃពីអ្នកផងនៅក្នុងសង្គមពិតប្រាកដ។

## VI-<u>សេចក្តីសន្និដ្ឋាន</u>

ដូចដែលមិត្តអ្នកអានបានជ្រាបហើយ នូវចំនុចទាំងប៉ុន្មានខាងលើ ដែលស្នេរខ្ញុំបានដកស្រង់អំពីខ្លឹមសារដ៏សំខាន់ទាំងបួននៃ **សង្គហធម៌ព្រះពុទ្ធសាសនា** ដែលជាសាសនាជាប់លំដាប់ថ្នាក់កំពូលផ្នែកខាងការអប់រំសីលធម៌ និងវប្បធម៌សន្តិភាព។ ជាការពិតណាស់,បើយើងពិនិត្យស្រាវជ្រាវឱ្យល្អិតល្អន់ទៅឃើញថាដទៃក្រៅអំពីព្រះពុទ្ធសាសនាមិនមានសាសនាណាមួយដែលសម្បូរទៅដោយពាក្យប្រៀនប្រដៅដែលប្រកបដោយហេតុផល,បាប,បុណ្យគុណ, ទោស, ធម៌អហិង្សា, សង្គហធម៌ ចរិយាធម៌, សីលធម៌, សុជីវធម៌ និងព្រហ្មវិហារធម៌ ជាងព្រះពុទ្ធសាសនានេះឡើយ។ ព្រះពុទ្ធសាសនាជានិច្ចកាល តែងតែបានដើរតួនាទីយ៉ាងសំខាន់ និងភ្ជាប់ខ្លួនដ៏ចាំបាច់ទៅនឹងសង្គមមនុស្សជាតិ ក្នុងការអប់រំផ្នែក





អភិសមាចារៈ(អាកប្បកិរិយាដ៏ត្រឹមត្រូវ និងមានសីលធម៌ក្នុងខ្លួន)និងការបង្ហាត់បង្រៀនមនុស្ស ឱ្យចេះរួបរួមសាមគ្គីស្រឡាញ់គ្នា និងព្យាយាមលុបបំបាត់ការប្រកាន់ពូជសាសន៍, ជាតិ, ត្រកូល, ពណ៌សម្បុរ, ទ្រព្យសម្បត្តិ និងកិត្តិយសបុណ្យស័ក្តិ ភេទ អំណាចជាដើម(non-discrimination)។ ទាំងអស់នេះដោយសារតែព្រះពុទ្ធសាសនាជាសាសនាមួយដែលផ្ទុកទៅដោយឃ្លាំងវចនៈនៃការអប់រំ (Bank of Educational Preachments) ទើបត្រូវបានគេគោរពប្រតិបត្តិ ដោយមនុស្សដែលជាបរិស័ទដ៏ច្រើនឥតគណនា បើទោះបីជាសាសនានេះមានអាយុកាលដ៏វែងជាង២៥៥០ឆ្នាំមកហើយក៏ដោយចុះ ហើយសព្វថ្ងៃនេះក៏ត្រូវបានមានការចាប់អារម្មណ៍ពីសំណាក់មនុស្សម្នានៅលើពិភពលោកកាន់តែច្រើនទៅៗដ៏គួរឱ្យកត់សំគាល់ ជាពិសេសនោះគឺ បណ្តាពួក **អ្នកដឹកនាំ, អង្គការជាតិនិងអន្តរជាតិ** ដែលកំពុងមានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើ**ការអនុវត្តសិទ្ធិមនុស្ស,ការមិនរើសអើង ប្រឆាំងនឹងមនុស្សជាតិ និងច្បាប់មនុស្សធម៌** ចំពោះពាក្យពេចន៍អប់រំដ៏ល្អៗឥតខ្ចោះដែលមាននៅក្នុងសាសនានេះនោះឯង។ ក្នុង

នោះដែរ, អ្វីដែលពិភពលោកមានការចាប់អារម្មណ៍ និងកំពុងបានយកចិត្តទុកដាក់ ហើយត្រូវបានដាក់បញ្ចូលជាគោលច្បាប់ **"សិទ្ធិមនុស្ស"**ពោលគឺ **សីល៥** (The Five Fundamental Precepts)និង **សង្គហធម៌៤** ដែលខ្ញុំបានលើកយកមកនិយាយនៅក្នុងសៀវភៅនេះឯង ។

**សង្គហធម៌ទាំង៤យ៉ាង** នោះខ្ញុំសូមសង្ខេបឡើងវិញគឺ **១_ទាន:** ការឱ្យ, ធ្វើអំណោយ, ចែករំលែក ឬក៏ការជួយជ្រោមជ្រែងឧបត្ថម្ភគ្នាទៅវិញទៅមក,**២_បិយវាចា:** ការពោលពាក្យពីរោះពិសា, ការនិយាយស្ដីដោយរួសរាយរាក់ទាក់ និងទន់ភ្លន់, **៣_លោកត្ថចរិយា:** ការលះបង់ចូលរួមចំណែកក្នុងការកសាងប្រយោជន៍សំរាប់មនុស្សទូទៅឬសាធារណ: និង **សមានត្តតា:** ការប្រព្រឹត្តខ្លួនស្មើមិនឆ្មើងឆ្មៃ, ការមិនប្រកាន់ខ្លួន, ការមិនរើសអើង និងការចេះបន្ទាបខ្លួនដោយល្អ មិនក្អេងក្អាង មិនព្រហើនច្រឡើសបើសច្រងេងច្រងាង និងចេះគោរពឱនលំទោនស្គាល់តូចស្គាល់ធំ និងចាស់ទុំជាដើម ។ ហើយខ្ញុំសូមឱ្យមនុស្សទាំងឡាយមានការអនុវត្តនូវគោលធម៌ទាំង៤នេះ ដោយសេចក្ដីគោរព





យ៉ាងខ្ជាប់ខ្ជួនក្នុងជីវិតប្រចាំថ្ងៃ ព្រោះថាបើគ្មានធម៌ទាំងនេះទេ ក៏ឈ្មោះថាមិនអាចស្វែងរកសុខសន្តិភាពបានឡើយ ។ ដរាបណាមនុស្សនៅតែ មានសេចក្ដីកំណាញ់,លោភលន់,កិបកេងលួចលាក់តែបន្លំ,មិនចេះចែករំលែកធ្វើទាន,មិនព្រមចូលរួមជ្រោមជ្រែងគ្នា (មច្ឆរិយភាព), នៅតែមានការពោលពាក្យគំរោះគំរើយ, ពាក្យមិនពិត, ពាក្យបញ្ជិតបញ្ជៀង, ពាក្យឥតប្រយោជន៍(ផរុសវាចា, មុសាវាទ, សម្ផប្បលាបនិងបិសុណវាចា), នៅតែប្រកាន់ផលប្រយោជន៍ផ្ទាល់ខ្លួន,មិនព្រមចូលរួមជួយកសាងប្រយោជន៍រួម ឬសាធារណប្រយោជន៍ (បរទត្ថភាព) និងនៅតែមានការប្រកាន់រើសអើង, ការតំកើងឬកក្រអឺតក្រទម ឬ ការព្រហើនកោងកាចអសីលធម៌, គ្មានសុជីវធម៌, គ្មានរបៀបរៀបរយ ខ្វះសណ្ដាប់ធ្នាប់ (អស្មិមានៈ)ដរាបនោះសង្គ្រាមផ្លូវចិត្តនៃការចងគំនុំគ្នា ក៏នៅតែមានផ្សែងជាប់មិនដាច់ដែរ ។

សូមព្យាយាមលះបង់ធម៌អាក្រក់ចេញពីក្នុងដួងចិត្តឱ្យបានគ្រប់ពេលទាំងអស់គ្នា ដើម្បីភាពសុខសាន្ត និងការរស់នៅប្រកបដោយការឯកភាពគ្នាក្នុងភាពជាបង-ប្អូន,ឪពុក-ម្ដាយនិងជាញាតិ

មិត្តសំឡាញ់នឹងគ្នា។ ដល់ពេលវេលាហើយ! មនុស្សយើងគួរតែឆ្អែតឆ្អន់នឹងការព្រាត់ប្រាស់, ការនិរាសបាត់បង់, ទុក្ខសោកក្រៀមក្រំនិងការបង្ហូរឈាមដោយសារ **សង្គ្រាម** ទៀតទៅ **សន្តិភាព** គឺជាភាពស្រស់បំព្រងនៃជីវិត ហើយក៏ជាអ្វីដែលយើងទាំងអស់គ្នាត្រូវការផងដែរ។

ពិភពលោកតំរូវឱ្យយើងសាងក្តី **សុខ** នោះគឺបានដល់ការបញ្ចប់នូវ **សង្គ្រាម** ហើយនាំគ្នារួបរួមសាមគ្គីស្រឡាញ់គ្នាដោយភាពមិនប្រកាន់រើសអើងភេទ,ពូជវង្សត្រកូល, ជាតិសាសន៍,វណ្ណៈតួនាទី, មានការគោរពសិទ្ធិគ្នា, គោរពច្បាប់មនុស្សធម៌ និងមាន **ព្រហ្មវិហារធម៌** ក្នុងចិត្តគ្រប់ៗគ្នា។

**សង្គមដែលប្រាថ្នាចង់បាននូវ សុខសន្តិភាព សុភមង្គល និងការអភិវឌ្ឍន៍** ដ៏ពិតប្រាកដ គឺត្រូវតែដើរតាមមាគ៌ានៃព្រះពុទ្ធសាសនាដោយអនុវត្តនូវគោលធម៌មានប្រការផ្សេងៗ ដូចជាការប្រតិបត្តិ **អរិយមគ្គទាំង៨ (មជ្ឈិមាបដិបទា),សីល៥** និងជាពិសេសគឺ **សង្គហធម៌៤** ដូចដែលខ្ញុំបានរៀបរាប់នៅក្នុងសៀវភៅនេះស្រាប់





ដែលជាគន្លឹះដ៏សំខាន់ក្នុងការបង្កើត **សុខសន្តិភាព** នៅលើពិភពលោកនេះ ហើយវាក៏មានភាពងាយស្រួលណាស់ដើម្បីប្រតិបត្តិព្រោះថាវាសាមញ្ញជាទីបំផុតមិនលំបាកឡើយ។ ហើយម្យ៉ាងទៀត សូមឱ្យមនុស្សគ្រប់គ្នាខិតខំធ្វើអំពើល្អ និងសិក្សារៀនសូត្រនូវខ្លឹមសារព្រះពុទ្ធវចនៈទាំងឡាយ ដែលមាននៅក្នុងព្រះពុទ្ធសាសនារួមជាមួយនឹងការប្រតិបត្តិដោយល្អ និងចងសម្ព័ន្ធមេត្រីចិត្តចំពោះគ្នាដើម្បីសេចក្តីសុខស្ងប់ក្សេមក្សាន្តសំរាប់ខ្លួនឯង និងសង្គមមនុស្សជាតិទូទៅទាំងអស់នៅលើពិភពលោកទាំងមូល។

**សូមឱ្យសុខសន្តិភាព**

**និងការអភិវឌ្ឍកើតមាននៅក្នុងលោក!!!**

**May Peace and Development prevail on Earth!!!**



## នាមសប្បុរសជនចូលបច្ច័យបោះពុម្ពសៀវភៅ
## “សង្គមធម៌ព្រះពុទ្ធសាសនា”

| ឈ្មោះ | ចំនួនថវិកា |
|---|---|
| ១-ភិក្ខុ លន់-សារិទ្ធិ សមណសិស្សពុ.វិ សម្ដេច បួរគ្រី | ៨០.០០០៛ |
| ២-ភិក្ខុ ជឹម-វ៉ាត សមណនិស្សិតសា.វិ ជាតិគ្រប់គ្រង | ២០.០០០៛ |
| ៣-ភិក្ខុ ឈួន-ល័ក្ខ សមណនិស្សិតពុ.សា.វិ ព្រះសីហនុរាជ | ២០.០០០៛ |
| ៤-ភិក្ខុ កែវ សុធា វិន័យធរវត្តមង្គលវ័ន | ២០០០០៛ |
| ៥-ភិក្ខុ សុខ បូរិន សមណសិស្សពុ.វិ សម្ដេចអ៊ុម ស៊ុម | ២០០០០៛ |
| ៦-ភិក្ខុ យឹម សានីរាន សមណសិស្សពុ.វិ ព្រះសុរាម្រឹត | ៣០០០០៛ |
| ៧-សាមណេរ ឌៀន វិសិដ្ឋ សមណសិស្សពុ.វិ ព្រះសុរាម្រឹត | ២០០០០៛ |
| ៨-ភិក្ខុ ជុន សូណា សមណសិស្សពុ.វិ សម្ដេចអ៊ុម ស៊ុម | ១០០០០៛ |
| ៩-ឧ.ស យឹម សារ៉ាន+ឧ.សិ ម៉ប់ ស៊ាម | ២០០០០៛ |
| ១០-ឧ.ស យឹម រី+ឧ.សិ យ៉ែន យ៉ាត+បុត្រ | ៣០០០០៛ |
| ១១-លោក អ៊ិន មត+ភរិយា | ៣០០០០៛ |
| ១២-ភិក្ខុ ឌិត-វីរៈ សមណនិស្សិតពុ.សា.វិ ព្រះសីហនុរាជ | ១៥.០០០៛ |
| ១៣-ភិក្ខុ រ៉េន-សារិទ្ធិ ចៅអធិការវត្តអង្គាញ់ (ស្មោង,ក.ធ) | ២០.០០០ |
| ១៤-ភិក្ខុ ខន-សុគន្ធី សមណសិស្សពុ.វិ ព្រះសុរាម្រឹត | ១៥.០០០៛ |
| ១៥-ឧ.សិ ពេន-យុត ប្រធានសីលវតីវត្តមង្គលវ័ន+កូនចៅ | ២០ ដុល្លារ |
| ១៦-ក្រុមគ្រួសារសពលោក យាយ កាំង ឆាំងឡាង | ១០.០០០០៛ |
| ១៧- ពុទ្ធបរិស័ទក្នុងកម្មវិធីបុណ្យ៧ថ្ងៃយាយ កាំងឆាំងឡាង | ៨០.០០០៛ |





| | |
|---|---|
| ១៨-ឧ.សិ ឃាវ សៀកឡៅ+ឃាវ គីមឡេង | ៨០.០០០៛ |
| ១៩- ឧ.សិ ពេជ្រ សុខន | ១៥០០០៛ |
| ២០- ឧ.ស ព្រុំ ង៉ិន+ឧ.សិ អ៊ិន ពៅ | ១០ ដុល្លារ |
| ២១-ឧ.សិ ពៅ វ៉ាន់ | ៣០០០៛ |
| ២២- ឧ.សិ រស់ សម្បត្តិ | ៣០០០៛ |
| ២៣-ឧ.សិ ប៉ែន សុខុម | ៥០០០៛ |
| ២៤- ឧ.សិ អ្ហួច ហាន | ១០០០០៛ |
| ២៥-ឧ.សិ គង់ ទូច+បុត្រ | ៥០០០៛ |
| ២៦-ឧ.សិ នូ ចាន់ថន | ៣០០០៛ |
| ២៧-ឧ.សិ គាង គុណ | ៣០០០៛ |
| ២៨-ឧ.សិ ចាន់ នឿន | ៦០០០៛ |
| ២៩-ឧ.សិ ហួយ យឿង+បុត្រ | ៤០០០៛ |
| ៣០-ឧ.សិ តឹក សុខសួ | ១០០០០៛ |
| ៣១-ឧ.សិ សំ ភាព | ៨០០០៛ |
| ៣២-ឧ.សិ ណៃ ហេង | ២០០០៛ |
| ៣៣-ឧ.សិ ម៉ែន ថៃ | ១០០០០៛ |
| ៣៤-ឧ.សិ ឯក សៀ | ៥០០០៛ |
| ៣៥-ឧ.សិ ផ្លុង រ៉ុម | ៣០០០៛ |
| ៣៦-ឧ.សិ វ៉ាន ស៊ីណា | ៥០០០៛ |
| ៣៧-ឧ.សិ ម៉ែន សាន់ | ៥០០០៛ |
| ៣៨-ឧ.សិ លាង | ៥០០០៛ |

| | |
|---|---|
| ៣៩-ឧ.សិ ម៉ៅ ទីម | ៥០០០៛ |
| ៤០-ឧ.សិ គង់ ថន | ១០០០០៛ |
| ៤១-ឧ.សិ គួច ណៃគី | ១០០០០៛ |
| ៤២-ឧ.សិ ពួ គួរេន | ៥០០០៛ |
| ៤៣-ឧ.សិ ពុធ ហួន | ៥០០០៛ |
| ៤៤-ឧ.សិ ភី សៀងហៃ | ១០០០០៛ |
| ៤៥-ឧ.សិ ដួង ហឿង | ១៥០០០៛ |
| ៤៦-ឧ.សិ យ៉ែម ហឿង | ៥០០០៛ |
| ៤៧-ឧ.សិ លឹម ម៉ុម | ៣០០០៛ |
| ៤៨-ឧ.សិ កែវ ណុន+បុត្រ | ១៥០០០៛ |
| ៤៩-ឧ.សិ គិន គឹមអួន+បុត្រ | ១០០០០៛ |
| ៥០-ឧ.ស ឡាយ តាវ | ៤០០០៛ |
| ៥១-ឧ.សិ សេង អេង | ១៥០០០៛ |
| ៥២-ឧ.សិ នង សុភី | ៥០០០៛ |
| ៥៣-ឧ.ស ហេង សុគាង+បុត្រ | ១០០០០៛ |
| ៥៤-ឧ.សិ ឆេង ចាន់ផល្លា | ១០០០០៛ |
| ៥៥-ឧ.សិ ង៉ាត់ | ២០០០៛ |
| ៥៦-ឧ.សិ សុត សុផល+បុត្រ | ៣០០០០៛ |
| ៥៧-ឧ.សិ សុត ចន្ទី+បុត្រ | ៣០០០០៛ |
| ៥៨-លោក យាយ សាន់ ងន+បុត្រ | ៣០០០០៛ |
| ៥៩-លោកយាយគង់ អេង+លោកស្រីគឹម ហុង+ស្វាមី+បុត្រ | ៥០០០០ |





| | |
|---|---|
| ៦០-ឧ.សិ ឯម ថា | ៣០០០៛ |
| ៦១-ឧ.សិ រ៉ូច | ៣០០០៛ |
| ៦២-ឧ.សិ ហុន សុផល | ៦០០០៛ |
| ៦៣-ឧ.សិ កែវ ប្រាក់ | ៣០០០៛ |
| ៦៤-ឧ.សិ ញ៉ែម ផល្លា | ៣០០០៛ |
| ៦៥-ឧ.សិ ស៊ុម ម៉ាលីន | ៣០០០៛ |
| ៦៦-ឧ.សិ រី | ៣០០០៛ |
| ៦៧-ឧ.សិ គឹម ហុន | ៣០០០៛ |
| ៦៨-ឧ.សិ បាន គឹមស្រាន | ៣០០០៛ |
| ៦៩-ឧ.សិ បាន មឿន | ៣០០០៛ |
| ៧០-ឧ.សិ តាន់ ប៊ុឆាយ | ៣០០០៛ |
| ៧១-ឧ.ស តាន់ សុវិទ្យា+ភរិយា | ៣០០០៛ |
| ៧២-លោក តាន់ យុវរដ្ឋ | ៣០០០៛ |
| ៧៣-ឧ.សិ កង ប៉ុញ | ២០០០០៛ |
| ៧៤-ឧ.សិ ហ៊ុន សុផា+បុត្រ | ៦០០០៛ |
| ៧៥-ឧ.ស អ៊ូ ហុង+ភរិយា+កូនចៅ | ២០០០០៛ |
| ៧៦-ឧ.សិ ហែម សុភាព | ១០០០០៛ |
| ៧៧-ឧ.សិ ជិង ងួន | ១៥០០០៛ |
| ៧៨-ឧ.សិ អុក សារឿន | ៥០០០៛ |
| ៧៩-ឧ.សិ នឹង ហ៊ីវ | ១៥០០០៛ |
| ៨០-ឧ.សិ លាង ខេមា | ១៥០០០៛ |

| | |
|---|---|
| ៨១-ឧ.ស យូ ហេង+ភរិយា+បុត្រ | ៥០០០៛ |
| ៨២-ឧ.សិ សាយ វួចហ៊ាង+បុត្រ | ៥០០០៛ |
| ៨៣-ឧ.សិ សួន ម៉ាឡៃ | ៥០០០៛ |
| ៨៤-ឧ.សិ រុំ | ២០០០៛ |
| ៨៥-ឧ.សិ យិន ផល | ២០០០៛ |
| ៨៦-ឧ.សិ ប៊ុន រ៉ែន | ៣០០០៛ |
| ៨៧-ឧ.សិ ព្រីង ហៃ | ៥០០០៛ |
| ៨៨-ឧ.សិ ថន +បុត្រ | ៣០០០៛ |
| ៨៩-អ្នកស្រី ហឿង(បារាំង)+បុត្រ | ១២០០០៛ |
| ៩០-ឧ.សិ នង ស៊ីផុន | ៩០០០៛ |
| ៩១-ឧ.សិ គុយ ឡាំងចេង+បុត្រ | ៦០០០០៛ |
| ៩២-ឧ.សិ ឃួន ភេន | ២០០០៛ |
| ៩៣-ឧ.សិ ឌួង យាម | ៩០០០៛ |
| ៩៤-ឧ.សិ ជឹម រស់ | ៣០០០៛ |
| ៩៥-ឧ.សិ ញ៉ែម សឿន | ៥០០០៛ |
| ៩៦-ឧ.សិ សោម យ៉ុន | ២០០០០៛ |
| ៩៧-ឧ.ស +ឧ.សិ អាយ យាត+ឧ.ស+ឧ.សិ ឆ្លាំង ម៉ៅ | ២០០០០៛ |
| ៩៨-ឧ.សិ អ៊ុក សារុន+ស្វាមី+បុត្រ | ២០០០០៛ |
| ៩៩-ឧ.សិ ឡើ ស៊ីឌីម+ស្វាមី+កូនចៅ | ២១០០០៛ |
| ១០០-លោកសុខ ឡាយ+ភរិយា+បុត្រ | ២០០០០៛ |
| ១០១-លោក ជ័រ | ២០០០០៛ |





| | |
|---|---|
| ១០២-លោកគ្រូ គង់ សុគុណ+ភរិយា(ក.ធ) | ១០០០០៛ |
| ១០៣-អ្នកគ្រូ គីង គីលីដា(ក.ធ) | ៥០០០៛ |
| ១០៤-លោកតាំង អៀកងួន | ១២០០០៛ |
| ១០៥-ឧ.ស ប្រាក់ ម៉ន+ភរិយា | ២០០០០៛ |
| ១០៦-ឧ.សិ នូ គិមសឿន | ៥០០០៛ |
| ១០៧-លោកធន់ ឈាន+ភរិយា | ៨០០០៛ |
| ១០៨-ឧ.សិ នុន សុភាព | ១០០០០៛ |
| ១០៩-ឧ.សិ ហ៊ុល ស៊ីណេត | ៥០០០៛ |
| ១១០-ឧ.សិ ទឹម ស៊ីថា | ៤០០០៛ |
| ១១១-ឧ.សិ ជា ណារិន | ៣០០០៛ |
| ១១២-ឧ.សិ អ៊ុង ឡុង | ៥០០០៛ |
| ១១៣-ឧ.សិ សៅ ផូ | ១០០០០៛ |
| ១១៤-ឧ.ស សំ ឡៃស៊ីម+ភរិយា+បុត្រ | ១០០០០៛ |
| ១១៥-ឧ.សិ ជ័យ អ៊ុក | ១០០០០៛ |
| ១១៦-ឧ.សិ គួក អំ | ៥០០០៛ |
| ១១៧-ឧ.សិ អ៊ី វណ្ណា | ៦០០០៛ |
| ១១៨-ឧ.សិ ទិត តុន | ២០០០៛ |
| ១១៩-ឧ.សិ ពុំ | ៣០០០៛ |
| ១២០-ឧ.សិ គុន សំបូរ | ៣០០០៛ |
| ១២១-ឧ.សិ សៅ ស៊ីគឿន | ៦០០០៛ |
| ១២២-ឧ.សិ កៅ សេដ្ឋា | ៣០០០៛ |

| | |
|---|---|
| ១២៣-ឧ.ស ឡោ ម៉ន+ភរិយា+បុត្រ | ១៥០០០៛ |
| ១២៤-ឧ.សិ យឹន លាង+បុត្រ | ៦០០០៛ |
| ១២៥-ឧ.សិ យូ អេងលីម+ស្វាមី+បុត្រ | ១៥០០០៛ |
| ១២៦-ឧ.សិ សំ ស៊ីផាន់ | ៣០០០៛ |
| ១២៧-ឧ.សិ លឹម សុត | ៣០០០៛ |
| ១២៨-ឧ.ស អ៊ុក សំណាង+ឧ.សិ ប៉ាល់ ធីតា+បុត្រ | ៨០០០៛ |
| ១២៩-សីលវតី ស៊ុយ លុយ | ៩០០០៛ |
| ១៣០-កញ្ញា សុន សុវណ្ណារី | ១០ដុល្លារ |
| ១៣១-កញ្ញា ម៉ឺន ពុទ្ធារី | ៥០០០៛ |
| ១៣២-ឧ.សិ លី អេង | ១០០០០៛ |
| ១៣៣-យុវជន អ៊ុក សុខា+មាតាបិតា+បងប្អូន | ៣០០០០៛ |
| ១៣៤-ឧ.សិ ហេង ប៊ុននាង+កូនចៅ | ១០០០០៛ |
| ១៣៥-ឧ.សិ លុយ គីម | ៥០០០៛ |
| ១៣៦-អ្នកស្រី ឯក សារុំ+ស្វាមី+បុត្រ | ៤០០០០៛ |
| ១៣៧-បងស្រី ទូច មុំ | ១០០០០៛ |
| ១៣៨-ឧ.ស វង ផេង+ភរិយា | ១០០០០៛ |
| ១៣៩-ឧ.ស វ៉ាន់ ប៉េងស្រ៊ន+ឧ.សិ ហាង ចាន់សេង | ១០០០០៛ |
| ១៤០-លោក សុភាព និងអ្នកស្រី វ៉ាន់ ចាន់ដា | ១០០០០៛ |
| ១៤១-លោក អ៊ា ណាត្រី+អ្នកស្រី ធីតា | ១០០០០៛ |
| ១៤២-ឧ.សិ ឡៃ គិម+ស្វាមី+បុត្រ | ៣០០០៛ |
| ១៤៣-ឧ.សិ មាស សំអួន+ស្វាមី | ៣០០០៛ |





| | |
|---|---|
| ១៤៤-អ្នកស្រី អ៊ុក ស៊ីធឿន+ស្វាមី+បុត្រ | ៥ ដុល្លារ |
| ១៤៥-ឧ.សិ លុយ វួច ឆេង | ៥០០០៛ |
| ១៤៦-ឧ.សិ ខូវ គីមឡេង | ៥០០០៛ |
| ១៤៧-លោក ប៉េង ស៊ីម | ៥០០០៛ |
| ១៤៨-ឧ.សិ ជា ធិចឡាង | ៥ដុល្លារ |
| ១៤៩-អ្នកស្រី តាំង ស៊ូឆេង | ៥ដុល្លារ |
| ១៥០-លោក តាំង ធង់ឆាយ | ៥ដុល្លារ |
| ១៥១-លោក តាំង ធង់ឡេង | ៥ដុល្លារ |
| ១៥២-អ្នកស្រី តាំង ស៊ូគាង និង ស្វាមី | ៥ដុល្លារ |
| ១៥៣-អ្នកស្រី តាំង ស៊ូឆេ និង ស្វាមី | ៥ដុល្លារ |
| ១៥៤-អ្នកស្រី តាំង ស៊ូហ៊ាង និង ស្វាមី | ៥ដុល្លារ |
| ១៥៥-ឧ.សិ ជូ គីមនី និង ស្វាមី ព្រមទាំងកូនចៅ | ៥ដុល្លារ |
| ១៥៦-ឧ.សិ លីម ណាលី និង កូនចៅ | ១០០០០៛ |
| ១៥៧-លោក អ៊ែ សុភក្ត្រ និង ភរិយា | ១០០០០៛ |
| ១៥៨-លោក អ៊ែ ឫទ្ធី និង ភរិយា | ១០០០០៛ |
| ១៥៩-ឧ.សិ តាំង អ៊ែគាង និង កូនចៅ | ១៥០០០៛ |
| ១៦០-ឧ.សិ សុត សំអាត | ២០០០០៛ |
| ១៦១-ឧ.សិ ង៉ែត ឆាងហ៊ាង | ១៥០០០៛ |
| ១៦២-ឧ.សិ សៅ សុគន្ធ និង បុត្រធីតា | ១០០០០៛ |
| ១៦៣-ឧ.សិ សូ ស៊ុនណារី និង កូនចៅ | ១០០០០៛ |
| ១៦៤-ពុទ្ធបរិស័ទថ្ងៃសីល ទី៧.១០.០៨ | ៩៤០០០៛ |